ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៤ សរណន

# សារាចរណែនាំ
# ស្តីពី
# ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨

## ១. សេចក្តីផ្តើម

១- មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានចែងអំពីប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំជា ៣ ដំណាក់កាល រួមមាន **ដំណាក់កាលទី១** គឺការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចាប់ពីខែមីនា ដល់ ខែឧសភា, **ដំណាក់កាលទី២** គឺការរៀបចំកញ្ចប់ថវិកា ចាប់ពីខែមិថុនា ដល់ខែកញ្ញា និង**ដំណាក់កាលទី៣** គឺការអនុម័តថវិកា ចាប់ពីខែតុលា ដល់ខែធ្នូ។ សម្រាប់ដំណាក់កាលទី១ រាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញរួចហើយនូវក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨។ ផ្អែកលើក្របខណ្ឌគោលនយោបាយនេះ រាជរដ្ឋាភិបាល ក៏បានដាក់ចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៨ ដើម្បីឱ្យគ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមឱវាទក្រសួង-ស្ថាប័ននីមួយៗ ធ្វើការពន្យល់និងផ្តល់អំណះអំណាងអំពីលទ្ធភាព និងកិច្ចខិតខំក្នុងការប្រមូលចំណូល និងបង្ហាញអំពីតម្រូវការចំណាយរយៈពេល ៣ ឆ្នាំ (២០១៨-២០២០) សម្រាប់អនុវត្តគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ននីមួយៗ ដែលជាការរួមចំណែកអនុវត្ត "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣**" និង "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨**" ។ នៅដំណាក់កាលទី២ នេះ រាជរដ្ឋាភិបាល ត្រូវចេញសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដើម្បីផ្តល់គោលការណ៍ណែនាំថ្មីៗសម្រាប់ជាមូលដ្ឋាន និងជាក្របខណ្ឌនៃការរៀបចំកញ្ចប់ថវិកាឆ្នាំ២០១៨ របស់គ្រប់ក្រសួង-ស្ថាប័ន ដោយគ្របដណ្តប់ទាំងថវិកាមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលជារដ្ឋបាលថ្នាក់ជាតិ។ ដូច្នេះ សារាចរនេះបានដាក់ចេញនូវក្របខណ្ឌ និងវិធានការប្រមូលចំណូល, ការកំណត់អាទិភាពចំណាយតាមវិស័យ និងគោលការណ៍សំខាន់ៗសម្រាប់បង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា ដោយផ្អែកលើលទ្ធភាពជាក់ស្តែងនៃថវិកាជាតិ អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងប្រសិទ្ធភាពនៃការអនុវត្តថវិការបស់ក្រសួង-ស្ថាប័ន នាឆ្នាំកន្លងមក។ ដោយឡែកចំពោះការរៀបចំកញ្ចប់ថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានសារាចរណែនាំមួយផ្សេងទៀត ដែលត្រូវដាក់ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១

ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១១, ដោយឈរលើមូលដ្ឋាន និងគោលការណ៍ដែលមានចែងនៅក្នុងសារាចរណែនាំនេះ ជាពិសេសគោលការណ៍នៃការកំណត់កញ្ចប់ និងគោលការណ៍នៃការវិភាជថវិកា ដើម្បីចូលរួមបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការប្រមូលចំណូល, ប្រសិទ្ធភាពនៃការវិភាជថវិកា និងស័ក្តិសិទ្ធភាពនៃការអនុវត្តចំណាយទាំងកម្រិតបច្ចេកទេស និងប្រតិបត្តិការ ក្នុងគោលដៅរួមចំណែកកាត់បន្ថយឱនភាពថវិកា និងរក្សាអតិរេកសាច់ប្រាក់។

២- ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ គឺស្ថិតក្នុងបរិការណ៍ដែលព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងក្រេបជញ្ជក់នូវផ្លែផ្កានៃសុខសន្តិភាព ឯកភាពជាតិ និងស្ថិរភាពនយោបាយ, ប្រកាន់ខ្ជាប់នូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស, ព្រមទាំងសម្រេចបាននូវការអភិវឌ្ឍ និងរីកចម្រើនលើគ្រប់វិស័យ ជាពិសេសការប្រែក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតទាបចាប់តាំងពីឆ្នាំ ២០១៥ ។ សមិទ្ធផលដ៏ធំធេងនេះបានបង្កើតមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាឱ្យកាន់តែរឹងមាំ និងបង្កលក្ខខណ្ឌកាន់តែអំណោយផល និងស្ថានភាពអនុគ្រោះសម្រាប់ការកសាងអនាគតកម្ពុជាមួយដ៏រុងរឿង និងត្រចះត្រចង់ ព្រមទាំងបានផ្តល់នូវឱកាស និងភាពងាយស្រួលដល់រាជរដ្ឋាភិបាលក្នុងការបន្តអនុវត្តការកែទម្រង់ឱ្យកាន់តែស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយដើម្បីឆ្លើយតបទៅតាមឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាជនកម្ពុជាផង និងដើម្បីឆ្លើយតបទៅនឹងដំណើរការនៃការផ្លាស់ប្តូររចនាសម្ព័ន្ធរបស់សង្គម-សេដ្ឋកិច្ចកម្ពុជាផង ក៏ដូចជាការប្រែប្រួលនិមាបនកម្មសេដ្ឋកិច្ច និងភូមិសាស្ត្រនយោបាយ ទាំងក្នុងកម្រិតតំបន់ និងពិភពលោកផង។

៣-ការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចពិភពលោកក្នុងពេលថ្មីៗនេះ បានបង្ហាញថាកំណើនរឹងមាំជាងការរំពឹងទុកនៃសេដ្ឋកិច្ចរបស់ប្រទេសអាមេរិក និងចិន ព្រមទាំងសន្ទុះកំណើនខ្ពស់នៃប្រទេសដែលមានសេដ្ឋកិច្ចកំពុងលូតលាស់ និងប្រទេសក្នុងតំបន់អាស៊ាន កំពុងជំរុញឱ្យមានភាពប្រសើរឡើងនៃសេដ្ឋកិច្ចពិភពលោក។ ទោះជាយ៉ាងនេះក្តី ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោក គឺនៅតែមាននៅឡើយដោយសារការលេចឡើងនូវចរន្តប្រឆាំងសកលភាវូបនីយកម្ម, ការការពារនិយមដែលរាំងខ្ទប់ការធ្វើពាណិជ្ជកម្មសេរី, ការកើនឡើងនូវការប្រើប្រាស់គោលនយោបាយប្រជាភិថុតិនិយមនៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចលូតលាស់ និងការប្រឆាំងនឹងការធ្វើអន្តោប្រវេសន៍ ដែលនិន្នាការបែបជាតិនិយមទាំងនេះ បានជះឥទ្ធិពលអវិជ្ជមាន (Negative Spillovers) ដល់ប្រទេសដទៃទៀត និងកំពុងបង្កើតភាពស្មុគស្មាញ និងភាពមិន-ប្រាកដប្រជាកាន់តែខ្លាំងដល់ស្ថានភាពភូមិសាស្ត្រនយោបាយ និងបញ្ហាសន្តិសុខពិភពលោក ក៏ដូចជាបង្កើនហានិភ័យកាន់តែខ្ពស់ដល់សេដ្ឋកិច្ច ពាណិជ្ជកម្ម និងហិរញ្ញវត្ថុសកលលោក តំបន់ និងប្រទេស។ លើសពីនេះ ការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិក, ការចាកចេញរបស់ប្រទេសអង់គ្លេស និងភាពមិនច្បាស់លាស់នៃតំបន់អឺរ៉ុប, ការថមថយនៃកំណើនរបស់សេដ្ឋកិច្ចចិន, ភាពមិនច្បាស់លាស់នៃគោលនយោបាយសេដ្ឋកិច្ច និងពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក, ការងើបឡើងវិញនូវតម្លៃប្រេង និងទំនិញលើទីផ្សារអន្តរជាតិ អាចបង្កើតជាហានិភ័យសម្រាប់សេដ្ឋកិច្ចកម្ពុជាផងដែរ។

ចំពោះហានិភ័យក្នុងប្រទេស, ការវិភាគបានបង្ហាញថា សេដ្ឋកិច្ចកម្ពុជាបានឈានដល់ចំណុចមួយដែលចាំបាច់ត្រូវជំរុញអនុវត្តឱ្យបានខ្លាំងក្លានូវវិធានការមុតស្រួច និងយុទ្ធសាស្ត្រចាំបាច់បន្ថែមនៅក្នុងវិស័យមួយចំនួន ព្រោះកំណើនខ្ពស់ប្រកបដោយចិរភាព, ក្នុងរយៈពេលជាងពីរទសវត្សរ៍មកនេះ, បានពឹងផ្អែកលើវិស័យកសិកម្ម វិស័យកាត់ដេរ វិស័យសំណង់ និងវិស័យទេសចរណ៍ ដែលវិស័យទាំងនេះបាននិងកំពុង

បង្ហាញនូវសញ្ញាថមថយមួយចំនួន។ ទន្ទឹមនេះ កម្ពុជាក៏កំពុងបន្តប្រឈមនឹងបញ្ហាសេដ្ឋកិច្ចផ្ទៃក្នុងមួយចំនួនទៀត រួមមាន តម្លៃអគ្គិសនីនៅខ្ពស់សម្រាប់វិនិយោគិន ធៀបជាមួយនឹងប្រទេសជិតខាង បើទោះជាតម្លៃនេះបានធ្លាក់ចុះហើយក្ដី, ការកើនឡើងជាលំដាប់នៃបៀវត្សអប្បបរមា ដែលធ្វើឱ្យសឹករិចរិលនូវភាពប្រកួតប្រជែងរបស់កម្ពុជាធៀបនឹងប្រទេសមួយចំនួនទៀត ដែលមានស្ថានភាពសេដ្ឋកិច្ចប្រហាក់ប្រហែលនឹងកម្ពុជា, ភាពមិនទាន់ឆ្លើយឆ្លងស៊ីសង្វាក់គ្នាពេញលេញរវាងសមត្ថភាពជំនាញ និងផលិតភាពរបស់ពលករកម្ពុជាជាមួយនឹងសេចក្ដីត្រូវការនៃទីផ្សារ និងតម្រូវការនៃការអភិវឌ្ឍ និងសម្ពាធនៃថ្លៃម្ហូបអាហារ ជាដើម ។

៤- ជារួម ទោះបីកម្ពុជាត្រូវជួបប្រទះនូវបញ្ហាប្រឈមគ្រប់បែបយ៉ាងទាំងក្នុង និងក្រៅប្រទេសក៏ដោយក៏រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា, ចាប់តាំងតែពីដើមនីតិកាលរហូតមក, នៅតែអាចតស៊ូពុះពារ និងជំនះបាននូវរាល់ឧបសគ្គ និង ការលំបាកផងទាំងពួង ហើយធានាបាននូវប្រក្រតីភាពនៃដំណើរការសង្គម-សេដ្ឋកិច្ចកម្ពុជា។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាធានាបានល្អប្រសើរនូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, គ្រប់គ្រងអតិផរណាឱ្យស្ថិតក្នុងកម្រិតទាបសមរម្យ, ធានាស្ថិរភាពនៃអត្រាប្ដូរប្រាក់ ព្រមទាំងពង្រឹងឡើងថែមទៀតនូវសមត្ថភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ តាមរយៈការជំរុញការអនុវត្តវិធានការនានា សំដៅពន្លឿនពិពិធកម្មសេដ្ឋកិច្ច រួមមានជាអាទិ៍ ការបង្កើនផលិតភាពនៃវិស័យកសិកម្ម, ការកសាងមូលដ្ឋានសេដ្ឋកិច្ចជនបទ និងការធ្វើឱ្យកាន់តែល្អប្រសើរនូវបរិយាកាសអំណោយផលសម្រាប់ទាក់ទាញការវិនិយោគឯកជន ដែលប្រការទាំងអស់នេះបានបង្កើតការងារជូនប្រជាជនកម្ពុជា, ពិសេសយុវជន ជាច្រើនសែននាក់ក្នុងមួយឆ្នាំៗ។ ជាក់ស្ដែង, ក្នុងឆ្នាំ ២០១៦, ប្រទេសកម្ពុជាត្រូវបានធនាគារពិភពលោកចាត់ចូលក្នុងក្រុមប្រទេស **៦កខត្តករកំណើន** ទាំងប្រាំបីនៅក្នុងពិភពលោក (Olympians of Growth) ដែលមានកំណើនសេដ្ឋកិច្ចខ្ពស់និងរឹងមាំ ហើយជាងនេះទៅទៀត ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ក៏បានកោតសរសើរយ៉ាងខ្លាំងចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់កម្ពុជា ដែលបានផ្លាស់ប្ដូរពីប្រទេសក្រីក្រ និងមានជម្លោះផ្ទៃក្នុងរ៉ាំរ៉ៃ ទៅជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចលឿនបំផុតនៅតំបន់អាស៊ី ហើយបានប្រសិទ្ធនាមប្រទេសកម្ពុជា ជា "**ខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី**" ទៀតផង។

ដោយផ្អែកលើចំណុចខ្លាំង, កត្តាអំណោយផល, បញ្ហាប្រឈម និងហានិភ័យដូចបានគិតគូរខាងលើ ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ ត្រូវបានកំណត់ឈរលើមូលដ្ឋានសុទិដ្ឋិនិយម ជាមួយនឹងការប្រុងប្រយ័ត្នខ្ពស់ ដែលរួមមានខ្លឹមសារសំខាន់ៗ ដូចខាងក្រោម៖

## ២. ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៨

### ២.១- ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៨

៥- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០១៦ កន្លងមកនេះ នៅបន្តរក្សាភាពរឹងមាំក្នុងអត្រាកំណើន ៧,០% ដូចការប៉ាន់ស្មានកាលពីដើមឆ្នាំ ជាមួយនឹងអតិផរណាមធ្យមប្រចាំឆ្នាំក្នុងអត្រា ៣,០% និងអត្រាប្ដូរប្រាក់មធ្យមប្រមាណ ៤ ០៥៦ រៀល ក្នុងមួយដុល្លារសហរដ្ឋអាមេរិក។ ការបន្តមានកំណើនខ្ពស់បែបនេះបានធ្វើឱ្យចំណូលជាតិសរុបសម្រាប់ប្រជាជនម្នាក់ៗកើនឡើងដល់១ ៣០២ ដុល្លារអាមេរិក ជាកម្រិតចំណូលដែលកម្ពុជាត្រូវបានចាត់ទុកថា សម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប។

៦- នៅក្នុងឆ្នាំ ២០១៧ និង ឆ្នាំ២០១៨ តាមការព្យាករ កម្ពុជានឹងសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧,០% ហើយ ផ.ស.ស តាមថ្លៃចរន្តឆ្នាំ ២០១៧ ត្រូវបានប៉ាន់ស្មានស្មើនឹងចំនួន ៨៩ ៤៧៨ ប៊ីលានរៀល និង ផ.ស.ស តាមថ្លៃចរន្តឆ្នាំ ២០១៨ ត្រូវបានគ្រោងចំនួន ៩៩ ០២៣ ប៊ីលានរៀល។ កំណើននេះបានមកពី៖

-វិស័យកសិកម្ម ត្រូវបានព្យាករថានឹងបន្តកំណើនរឹងមាំក្នុងរង្វង់ ២,០% នៅឆ្នាំ២០១៧ និង ២០១៨ ដោយសារភាពអំណោយផលនៃកត្តាអាកាសធាតុ ដែលបានព្យាករដោយក្រសួងធនធានទឹក និងឧតុនិយម, គោលនយោបាយវិគ្គារកម្មរបស់រាជរដ្ឋាភិបាល ក្នុងការវិយោគបន្ថែមលើប្រព័ន្ធធារាសាស្ត្រខ្នាតតូច ពូជ ដំណាំ និងការផ្សព្វផ្សាយបច្ចេកទេស, ការចូលរួមកាន់តែសកម្មជាងមុនពីសំណាក់ដៃគូអភិវឌ្ឍន៍ និងក្រុមហ៊ុនឯកជនក្នុងការវិនិយោគលើវិស័យកសិកម្ម គួបផ្សំនឹងការបន្តកើនឡើងនៃតម្លៃកសិផលលើទីផ្សារអន្តរជាតិ។ ផលិតកម្មដំណាំឧស្សាហកម្ម និងដំណាំរួមផ្សំ ត្រូវបានប៉ាន់ស្មានថានឹងបន្តកំណើនខ្ពស់ ដែលទ្រទ្រង់ដោយការកើនឡើងនៃតម្លៃកៅស៊ូ និងការងើបឡើងវិញនៃតម្លៃកសិផលផ្សេងៗ ព្រមទាំងការកើនឡើងនៃការវិនិយោគលើវិស័យកសិឧស្សាហកម្ម ដូចជាការផលិតចំណីសត្វ, ប្រេងអេតាណុល និងស្កសរជាដើម។ អនុវិស័យកសិកម្មផ្សេងទៀត ដែលរួមមាន ជលផល និងការចិញ្ចឹមសត្វ ក៏ត្រូវបានព្យាករថានឹងបន្តកំណើនល្អ ដោយសារតែការរំពឹងទុកនៃការបន្តកើនឡើងការវិនិយោគលើវិស័យវារីវប្បកម្ម និងការចិញ្ចឹមមាន់ និងជ្រូក ដោយក្រុមហ៊ុនឯកជនក្នុងទម្រង់ជាកសិកម្មបែបកិច្ចសន្យា។ ដូចនេះ រាជរដ្ឋាភិបាលនឹងផ្តោតការផ្តល់អាទិភាពខ្ពស់ចំពោះការបង្កើតឱ្យមានផែនការរយៈពេលវែងដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីអភិវឌ្ឍវិស័យកសិកម្ម ដែលមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ពីផ្នែកសាធារណៈ, វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងឡាយ ដែលបាននិងកំពុងជួបប្រទះ៖ ផលិតភាពទាប, កង្វះការធ្វើពិពិធកម្មកសិកម្ម, កង្វះការវិនិយោគលើវិស័យកសិឧស្សាហកម្ម, ការចិញ្ចឹមសត្វ និងវារីវប្បកម្មបែបពាណិជ្ជកម្ម ព្រមទាំងភាពមានកម្រិតនៃការធ្វើពាណិជ្ជូបនីយកម្មនៃផលិតផលកសិកម្ម។

-វិស័យឧស្សាហកម្ម ត្រូវបានព្យាករថានឹងបន្តកំណើនរឹងមាំក្នុងអត្រា ១០,៧% នៅឆ្នាំ២០១៧ និង ១០,១% ក្នុងឆ្នាំ ២០១៨ ដែលគាំទ្រដោយវិស័យកាត់ដេរ និងសំណង់ ជាពិសេសវិស័យផលិតកម្មមិនមែនកាត់ដេរ។ វិស័យកាត់ដេរ រំពឹងថានឹងនៅបន្តកំណើនខ្ពស់ក្នុងអត្រា ៨,៥% ក្នុងឆ្នាំ ២០១៧ ដោយសារភាពល្អប្រសើរនៃស្ថានភាពសេដ្ឋកិច្ចសកល ជាពិសេសប្រទេសដែលជាដៃគូពាណិជ្ជកម្មសំខាន់ៗ ដូចជាសហរដ្ឋអាមេរិក និងអឺរ៉ុបជាដើម, ការងើបឡើងវិញនៃពាណិជ្ជកម្មអន្តរជាតិ និងការលុបចោលកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរប៉ាស៊ីហ្វិកជាដើម។ ដោយឡែក, វិស័យកាត់ដេរឆ្នាំ ២០១៨ អាចនឹងថមថយកំណើនបន្តិច ដែលអាចបណ្តាលមកពីស្ថានភាពមិនច្បាស់លាស់នៃការវិនិយោគក្នុងឆ្នាំបោះឆ្នោតសកល និងការប្រកួត-ប្រជែងកាន់តែខ្លាំងពីប្រទេសមីយ៉ាន់ម៉ា និងវៀតណាម ជាពិសេសនៅពេលដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងវៀតណាម និងសហភាពអឺរ៉ុបចូលជាធរមាន។ ក្នុងន័យនេះ, កម្ពុជាត្រូវផ្តោតសំខាន់លើការពង្រឹងភាពប្រកួតប្រជែងរបស់ខ្លួន ដើម្បីរក្សានិរន្តរភាពកំណើននៃវិស័យកាត់ដេរ ក៏ដូចជាការត្រៀមខ្លួនជាស្រេច ដើម្បីចាប់យកឱកាសនៃបម្លាស់ទីរោងចក្រចេញពីប្រទេសចិន។ វិស័យសំណង់ ត្រូវបានព្យាករថានឹងអាចថមថយកំណើនមកត្រឹម ១៤,១% និង ១២,៤% សម្រាប់ឆ្នាំ ២០១៧ និង ២០១៨ រៀងគ្នា ដោយសារឥរិយាបថ "រង់ចាំមើល" (Wait-and-See) របស់វិនិយោគិនក្នុងការវិនិយោគបន្ថែម និងកំណើននៃការផ្គត់ផ្គង់ដ៏ច្រើនលើសលប់ ធៀបនឹងតម្រូវការជាក់ស្តែង ចំពោះប្រភេទសំណង់លំនៅដ្ឋានដែលមានតម្លៃខ្ពស់។ ជានិន្នាការ ការសាងសង់ខុនដូរ និងបុរីដែលមានតម្លៃខ្ពស់មានសភាពនៅទ្រឹង ប៉ុន្តែ បានប៉ះប៉ូវដោយ

គម្រោងលំនៅដ្ឋានដែលមានតំលៃសមរម្យ, ការបន្តកើនឡើងនៃការសាងសង់សំណង់ការិយាល័យ និង សំណង់ផ្សេងៗទៀត, និន្នាការនៃការលូតលាស់យ៉ាងឆាប់រហ័សផ្នែកនគរូបនីយកម្មនៅរាជធានីភ្នំពេញ និង តាមខេត្តធំៗមួយចំនួន ក៏ដូចជាការកើនឡើងនៃវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត។ ទោះជា យ៉ាងនេះក្តី ការថមថយនៃវិស័យសំណង់ ត្រូវបានបំពេញបន្ថែមដោយកំណើនខ្ពស់នៃវិស័យឧស្សាហកម្ម ផ្សេងៗ ដូចជា អាហារ និង ភេសជ្ជៈ, គ្រឿងបង្គុំអេឡិចត្រូនិច, គ្រឿងបន្លាស់, វិស័យថាមពល និងវិស័យ ផលិតកៅស៊ូក្រេបជាដើម។ គម្រោងបង្កើនការផលិតអាហារ និងភេសជ្ជៈក្នុងស្រុកបន្ថែមទៀតនាឆ្នាំ ២០១៧ និង២០១៨ ជំនួសឱ្យការនាំចូល នឹងធ្វើឱ្យវិស័យនេះរួមចំណែកកាន់តែធំជាងមុននៅក្នុងសេដ្ឋកិច្ចជាតិ។ វិស័យគ្រឿងបង្គុំអេឡិចត្រូនិច និង គ្រឿងបន្លាស់រថយន្តក៏នឹងមានសន្ទុះខ្លាំងផងដែរ ដោយសារវិនិយោគិន ជប៉ុនបានបន្តបង្កើតរោងចក្រថ្មីបន្ថែមទៀតក្នុងតំបន់សេដ្ឋកិច្ចពិសេសនៅទីក្រុងប៉ោយប៉ែត សម្រាប់បម្រើការ នាំចេញទៅក្រៅប្រទេស។ កំណើននៃវិស័យថាមពល ដោយសារកំណើននៃការផ្គត់ផ្គង់អគ្គិសនីពីទំនប់ វារីអគ្គិសនីក្នុងស្រុកមួយចំនួន នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយបរិមាណអគ្គិសនីដែលនាំចូល ពីប្រទេសជិតខាង និងធ្វើឱ្យតម្លៃអគ្គិសនីនៅកម្ពុជាកាន់តែមានកម្រិតសមរម្យជាងមុន។ ការអនុវត្តយុទ្ធសាស្ត្រ ចិនបូក ១ និងថៃបូក ១ ក៏នឹងចូលរួមពង្រឹងភាពប្រកួតប្រជែង និងការធ្វើពិពិធកម្មផលិតកម្មក្នុងស្រុកឱ្យ បានកាន់តែប្រសើរផងដែរ។ ដើម្បីជំរុញឱ្យវិស័យឧស្សាហកម្មរួមចំណែកកាន់តែប្រសើរឡើងក្នុងសេដ្ឋកិច្ច ជាតិ, រាជរដ្ឋាភិបាលនឹងត្រូវខិតខំទ្វេដងក្នុងការទាក់ទាញការវិនិយោគផ្ទាល់ពីក្រៅប្រទេស ដើម្បីបំពេញនូវ ការថមថយការវិនិយោគក្នុងស្រុក ដោយសារភាពមិនប្រាកដប្រជានាឆ្នាំ ២០១៨ ខាងមុខ; ជំរុញការអនុវត្ត គោលនយោបាយឧស្សាហកម្ម ដែលជាយុទ្ធសាស្ត្រកំណើនថ្មីរបស់ជាតិឱ្យមានសន្ទុះខ្លាំងក្លាឡើង សំដៅ ជំរុញល្បឿននៃការធ្វើពិពិធកម្មមូលដ្ឋានឧស្សាហកម្មឱ្យកាន់តែឆាប់រហ័ស ដើម្បីបង្កើនភាពប្រកួតប្រជែង បង្កើនតម្លៃបន្ថែមឱ្យកាន់តែខ្ពស់ក្នុងខ្សែចង្វាក់ផលិតកម្មក្នុងស្រុក និងចាត់វិធានការមុតស្រួចដើម្បីកាត់ បន្ថយចំណាយធុរៈកិច្ចដែលនៅខ្ពស់ និងសម្រួលនីតិវិធីក្នុងការធ្វើធុរកិច្ចឱ្យកាន់តែរលូនជាងមុន។

-វិស័យសេវាកម្ម ត្រូវបានព្យាករថានឹងបន្តនូវកំណើនខ្ពស់ប្រហាក់ប្រហែលនឹងឆ្នាំ ២០១៦ ក្នុងរង្វង់ ៦,៥% សម្រាប់ឆ្នាំ ២០១៧ និង ៦,៧% នាឆ្នាំ ២០១៨ ដោយសារកំណើនរឹងមាំនៃវិស័យលក់ដុំ និង លក់រាយ និងវិស័យគមនាគមន៍ ទោះបីវិស័យវិស័យទេសចរណ៍នៅបន្តកំណើនយឺត និងការថមថយនៃ កំណើនក្នុងវិស័យអចលនទ្រព្យ និងដឹកជញ្ជូន។ កំណើននៃវិស័យទេសចរណ៍ ត្រូវបានព្យាករថានៅទ្រឹង ប្រមាណ ២,៣% ក្នុងឆ្នាំ២០១៧ និង២០១៨ ដោយសារតែកង្វះការធ្វើពិពិធកម្មទាំងលើផលិតផល សេវាកម្ម ទិសដៅទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ ព្រមទាំងការបន្តកើនឡើងនៃប្រាក់ដុល្លារ អាមេរិក។ វិស័យអចលនទ្រព្យ ក៏ត្រូវបានព្យាករថានឹងបន្តថមថយកំណើនមកត្រឹម ៨,៣% និង ៧,៩% សម្រាប់ឆ្នាំ ២០១៧ និង២០១៨ រៀងគ្នា ដែលនិន្នាការនេះស្របគ្នានឹងការថមថយកំណើននៃវិស័យសំណង់ និងដែលឆ្លុះបញ្ចាំងតាមរយៈការថមថយឥណទានផ្តល់ឱ្យទៅវិស័យនេះ ការថមថយនៃតម្រូវការធៀបនឹងការ ផ្គត់ផ្គង់ ព្រមទាំងបរិបទនៃភាពមិនច្បាស់លាស់នៃស្ថានភាពវិនិយោគនាឆ្នាំខាងមុខ។ វិស័យដឹកជញ្ជូន និង ទំនាក់ទំនង ត្រូវបានព្យាករថានឹងបន្តកំណើនយឺតជាងមុនបន្តិចមកត្រឹម ៧,៥% និង ៧,៤% រៀងគ្នា ដោយ សារកំណើនយឺតនៃវិស័យផ្សេងៗទៀតដូចជាកាត់ដេរ, សំណង់, និងទេសចរណ៍ជាដើម ទោះបីជាវិស័យ ទំនាក់ទំនងនឹងមានសន្ទុះកំណើនខ្ពស់នាឆ្នាំខាងមុខ។ ដោយឡែក កំណើនខ្ពស់នៃវិស័យលក់ដុំ និងរាយ នឹងអាចប៉ះប៉ូវដល់ការថមថយទាំងនេះ ពោលគឺវិស័យនេះត្រូវបានព្យាករថានឹងកើនឡើងជាបន្តបន្ទាប់ក្នុង

អត្រា ៧,៨% និង៨,៣% រៀងគ្នា ស្របនឹងកំណើននៃតម្រូវការក្នុងស្រុក ដែលឆ្លុះបញ្ចាំងអំពីនិន្នាការនៃការផ្លាស់ប្តូររបៀបរបបរស់នៅរបស់យុវវ័យ ព្រមទាំងការកើនឡើងនៃប្រាក់ចំណូលរបស់ប្រជាពលរដ្ឋដោយសារគោលនយោបាយវិត្តារកម្មថវិការបស់រាជរដ្ឋាភិបាលក្នុងការបង្កើនបៀវត្សជូនមន្ត្រីរាជការ និងការកើនឡើងនៃបៀវត្សអប្បបរមានៃវិស័យឯកជន។ រាជរដ្ឋាភិបាលនឹងបន្តផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រងវិស័យអចលនទ្រព្យ តែខិតខំជំរុញការអភិវឌ្ឍលំនៅស្ថានដែលមានតម្លៃសមរម្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងវិនិយោគបន្ថែមលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសំខាន់ៗផ្សេងទៀត ដោយផ្អែកលើផែនការមេមួយច្បាស់លាស់ ជាពិសេសចំពោះវិស័យទូរគមនាគមន៍ និងដឹកជញ្ជូន និងវិស័យថាមពល ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពនៃចំណាយទាំងនេះ។ ទាក់ទងនឹងវិស័យហិរញ្ញវត្ថុ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងយន្តការគ្រប់គ្រងហានិភ័យ និងវិបត្តិហិរញ្ញវត្ថុ, ទ្រទ្រង់កំណើនឥណទានឱ្យស្ថិតក្នុងកម្រិតសមស្របមួយ និងបង្កើនគុណភាពនៃការផ្តល់ឥណទាន ដោយផ្តោតលើវិស័យផលិតកម្ម និងពាណិជ្ជកម្ម, បន្តខិតខំស្វែងរកប្រភពទុនថ្មីៗបន្ថែមទៀតសម្រាប់វិស័យឯកជន ជាពិសេសការអភិវឌ្ឍទីផ្សារសញ្ញាបណ្ណ (Bond Market) និងទីផ្សាររូបិយប័ណ្ណ (Money Market) និងបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋទូទៅ ជាពិសេសប្រជាពលរដ្ឋនៅតាមទីជនបទ ពាក់ព័ន្ធនឹងកម្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុ ព្រមទាំងបន្តពិនិត្យលទ្ធភាពបញ្ចុះថែមទៀតនូវអត្រាការប្រាក់ក្នុងវិស័យទាំងនេះ។

- អតិផរណាត្រូវបានប៉ាន់ស្មានថានឹងបន្តស្ថិតនៅក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន ទោះបីតម្លៃប្រេងត្រូវបានព្យាករថានឹងបន្តកើនឡើង គួបផ្សំនឹងសម្ពាធនៃតម្លៃម្ហូបអាហារ។ អត្រាអតិផរណាជាមធ្យមនៅឆ្នាំ ២០១៧ និងឆ្នាំ ២០១៨ ត្រូវបានរំពឹងថានឹងកើនឡើងដល់ ៣,៨% និង ៣,៥% រៀងគ្នា។ អត្រាប្តូរប្រាក់ត្រូវបានរំពឹងថានឹងមានស្ថិរភាព ដែលមានអត្រាជាមធ្យមគឺ ៤ ០៣៧ រៀលក្នុងមួយដុល្លារអាមេរិក នៅឆ្នាំ ២០១៧ និង២០១៨ខាងមុខ ដោយសារការបន្តរក្សាបាន កំណើនសេដ្ឋកិច្ចខ្ពស់ និងជំនឿទុកចិត្តពីសាធារណជន ពិសេសការបន្តអនុវត្តបានល្អប្រសើរ និងសមស្រប នៃគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ និងគោល-នយោបាយរូបិយវត្ថុក្នុងវិស័យហិរញ្ញវត្ថុសាធារណៈរបស់ ធនាគារជាតិនៃកម្ពុជា។

- ឱនភាពគណនីចរន្តត្រូវបានព្យាករថានឹងបន្តប្រសើរឡើង ក្នុងអត្រា ៧,៩% នៃ ផ.ស.ស នា ឆ្នាំ ២០១៧ និង ៨,៥% នៃ ផ.ស.ស នៅឆ្នាំ ២០១៨។ ភាពប្រសើរឡើងនេះ ស្តែងចេញតាមរយៈការកើនឡើងជាលំដាប់នៃសមត្ថភាពនាំចេញរបស់កម្ពុជា ស្របពេលដែលផលិតផល និងវត្ថុធាតុដើមមួយចំនួនចាប់ផ្តើមមានមូលដ្ឋានផលិតនៅក្នុងស្រុកជំនួសឱ្យការនាំចូលជាបណ្តើរៗ។ នៅឆ្នាំ២០១៧ ទុនបម្រុងនឹងមានទំហំ ៧ ៥៣៨ លានដុល្លារអាមេរិក ហើយនឹងអាចកើនឡើងដល់ ៧ ៨៥៣ លានដុល្លារអាមេរិក នាឆ្នាំ ២០១៨ ដែលអាចធានាបានជាមធ្យមប្រមាណជា ៥,៦ ខែ នៃការនាំចូលទំនិញ និងសេវាទាំងអស់។

- ជារួម ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះត្រូវបានរៀបចំឡើង ដើម្បីរក្សាឱ្យបានស្ថិរភាពម៉ាក្រូ-សេដ្ឋកិច្ចតាមរយៈការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព, ស្ថិរភាពតម្លៃ, ការបង្កើតការងារ និងចីរភាពបំណុល។ ដើម្បីសម្រេចគោលបំណងខាងលើ រាជរដ្ឋាភិបាលកំណត់គោលដៅកំណើន ផ.ស.ស ឱ្យ សម្រេចបានប្រមាណ ៧,០% សម្រាប់ឆ្នាំ ២០១៧ និងឆ្នាំ ២០១៨។ រាជរដ្ឋាភិបាលនឹងខិតខំគ្រប់គ្រងអតិផរណាជាមធ្យមប្រចាំឆ្នាំឱ្យស្ថិតក្នុងរង្វង់ ៣,៥% ក្នុងមួយឆ្នាំ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល នឹងបន្តធានាឱ្យបានស្ថិរភាពអត្រាប្តូរប្រាក់រៀលឱ្យស្ថិតនៅក្នុងរង្វង់ ៤ ០៥០ រៀលក្នុងមួយដុល្លារអាមេរិក ដោយខិតខំជំរុញលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលក្នុងរយៈពេលមធ្យម និង រយៈពេលវែង។

## ២.២- ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ២០១៨

៨- ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង ថវិកាឆ្នាំ២០១៨ ត្រូវបានរៀបចំដោយឈរលើមូលដ្ឋាននៃក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៨ និង "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣**" និង "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**" ដោយមានគោលបំណងសំខាន់ៗ ដូចតទៅៈ

- បន្តជានាអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដើម្បីបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កានៃកំណើន ប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន,
- បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ និងធានាការពារអធិបតេយ្យ និងបូរណភាពទឹកដី,
- បន្តធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ព្រមទាំងធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព,
- បន្តផ្តល់អាទិភាពដល់ការដំឡើងប្រាក់បៀវត្សរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ឆ្ពោះទៅសម្រេចគោលដៅឱ្យបានជាង ១ លានរៀល នៅឆ្នាំ២០១៨ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងបង្កើនកម្រិតជីវភាពរបស់មន្ត្រីរាជការឱ្យកាន់តែល្អប្រសើរ, ដោយផ្សារភ្ជាប់ទៅនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ (២០១៥-២០១៨), ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ,
- បន្តខិតខំប្រឹងប្រែងខ្លាំងក្លាជាងមុនក្នុងការប្រមូលចំណូល ដើម្បីបន្តសម្រេចបានតាមទិសដៅដាក់ចេញក្នុង**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម (២០១៤-២០១៨)** ជាពិសេស គឺរក្សាបានចីរភាពចំណូលជាមួយនឹងកំណើនខ្ពស់ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក,
- ខិតខំរក្សាឱ្យបាននូវលំហថវិកាសមស្រប រួមទាំងយន្តការគ្រប់គ្រងវិបត្តិ ដើម្បីទប់ទល់វិបត្តិកលិយុគ និងហានិភ័យផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ, ទន្ទឹមនឹងការបង្កើនចំណាយវិនិយោគផ្ទាល់ដោយថវិកាជាតិ ដើម្បីបង្កើនឯករាជ្យភាពនៃថវិកា និងកាត់បន្ថយជាបណ្តើរៗនូវការពឹង-ផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស,
- បន្តពង្រឹងការអនុវត្តគោលនយោបាយគ្រប់គ្រងបំណុលសាធារណៈ ឱ្យស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន និងប្រកបដោយចីរភាព,
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ការលើកកម្ពស់សេវាសុខាភិបាល អាហារូបត្ថម្ភ និងសេវាសន្តិសុខសង្គម,
- បន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ទាំងផ្នែករឹង និងផ្នែកទន់សម្រាប់គាំទ្រកំណើន និងការអភិវឌ្ឍ ជាពិសេស ផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ប្រព័ន្ធធារាសាស្ត្រស្រោចស្រព អគ្គិសនី ទឹកស្អាត សាលារៀន និង មន្ទីរពេទ្យ ។ល។ *ព្រមជាមួយនឹងការផ្តល់អាទិភាពលើហេដ្ឋារចនាសម្ព័ន្ធថ្មីៗ និងសកម្មភាពអភិវឌ្ឍន៍វិស័យកសិកម្ម ដែល*

*មានភាពធន់ទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងការផ្ទុះជំងឺ ដើម្បីបញ្ចៀសការខូចខាតពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយទៅលើការអភិវឌ្ឍសេដ្ឋកិច្ច,*

- បន្តផ្តល់អាទិភាពដល់សកម្មភាពថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលបានកសាងរួច ជាពិសេស ផ្លូវថ្នល់ និង ប្រព័ន្ធធារាសាស្ត្រស្រោចស្រព,
- បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្មនិងវិស័យគាំទ្រ ដើម្បីជំរុញផលិតភាព តម្លៃបន្ថែម និង ជំរុញការកែច្នៃ និងនាំចេញផលិតផលកសិ-ឧស្សាហកម្ម និងកសិផល ការចិញ្ចឹមសត្វ និងវារីវប្បកម្ម, រួមទាំងបន្តការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ,
- ជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា២០១៥-២០២៥,
- បន្តអនុវត្តកំណែទម្រង់សំខាន់ៗ រួមទាំង ការពង្រឹងស្ថាប័នសាធារណៈ និងប្រព័ន្ធអភិបាលកិច្ច,
- លើកកម្ពស់គុណភាព និងពង្រីកការទទួលបានភាពពេញចិត្ត និងប្រសិទ្ធភាពនៃសេវាសាធារណៈ
- ធានានូវកិច្ចដំណើរការដោយរលូន និងដោយជោគជ័យនៃការបោះឆ្នោតសកលឆ្នាំ២០១៨។

៩- ក្នុងបរិបទ និងទស្សនៈវិស័យម៉ាក្រូសេដ្ឋកិច្ច និងក្នុងទិសដៅសម្រេចឱ្យបាននូវគោលបំណងខាងលើ រាជរដ្ឋាភិបាលបានកំណត់ក្របខណ្ឌថវិកាឆ្នាំ២០១៨ រួមជាមួយនឹងវិធានការគោលនយោបាយជាក់លាក់ទាំងផ្នែកចំណូល និងផ្នែកចំណាយសម្រាប់ឆ្នាំ២០១៨ ដូចខាងក្រោម៖

## ២.២.១- ក្របខណ្ឌចំណូលថវិកាឆ្នាំ២០១៨

១០- គម្រោងចំណូលថវិកាឆ្នាំ២០១៨ ត្រូវបានកំណត់ដូចខាងក្រោម៖

- ចំណូលសរុបក្នុងប្រទេសថវិការដ្ឋសម្រាប់ឆ្នាំ២០១៨ គ្រោងសម្រេចឱ្យបាន ១៨,៧៨% នៃផ.ស.ស. គឺមានកំណើន ០,២១ ពិន្ទុភាគរយនៃផ.ស.ស. ឬ កើនឡើង ១១,៩% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ (ហៅកាត់ថា ច្បាប់ថវិកាឆ្នាំ២០១៧) ក្នុងនោះ ៖

- ចំណូលចរន្តថវិការដ្ឋត្រូវសម្រេចឱ្យបានប្រមាណ ១៨,៦០% នៃផ.ស.ស. គឺមានកំណើន ០,១៩ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១១,៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧។ **ចំណូលពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា** ត្រូវគ្រោងសម្រេចឱ្យបាន ៨,៤១% នៃផ.ស.ស. គឺមានកំណើន ០,២៤ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១៤,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧, **ចំណូលពីអគ្គនាយកដ្ឋានពន្ធដារ**ត្រូវគ្រោងសម្រេចឱ្យបាន ៦,៨១% នៃផ.ស.ស. គឺមានកំណើន ០,២២ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១៤,៣% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧, និង**ចំណូលមិនមែនសារពើពន្ធ** ត្រូវគ្រោងសម្រេចឱ្យបាន ២,៥០% នៃផ.ស.ស. គឺថយចុះ ០,១១ ពិន្ទុភាគរយនៃផ.ស.ស. ប៉ុន្តែមានកំណើន ៦,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧។
- **ចំណូលមូលធន**ក្នុងប្រទេស ត្រូវសម្រេចឱ្យបាន០,១៨% នៃផ.ស.ស. គឺមានកំណើន ០,០២ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ២១,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧។
- ចំណែកឯ **ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈ** គ្រោងសម្រេចឱ្យបាន ៤,៥៩%នៃផ.ស.ស. គឺថយចុះ ០,២០ ពិន្ទុភាគរយ នៃផ.ស.ស.

ឬកើនឡើង ៦,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧ ហើយ**មូលនិធិទ្រទ្រង់ថវិកា** គ្រោងសម្រេចឱ្យបាន ០,៣០%នៃផ.ស.ស.។

១១- ដើម្បីសម្រេចគោលដៅចំណូលសរុបខាងលើនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើការជំរុញ និងពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយសម្រាប់រយៈពេលខ្លី និងមធ្យម ស្របតាម **យុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨** ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ក្នុងផ្នែកគយនិងរដ្ឋាករ ផ្នែកពន្ធដារ និងផ្នែកមិនមែនសារពើពន្ធ។ ជាពិសេស រាជរដ្ឋាភិបាលនឹងបន្តប្រឹងប្រែងខ្លាំងក្លាជាងមុន ក្នុងការលើកកម្ពស់វប្បធម៌បង់ពន្ធ តាមរយៈការកែសម្រួលនិងការធ្វើសាមញ្ញកម្មនៃសេវាបង់ពន្ធដល់អ្នកបង់ពន្ធដើម្បីលើកកម្ពស់អនុលោមភាព, បន្តពង្រឹងការបង្ក្រាបអំពើរត់ពន្ធ និងការគេចវេះពន្ធគ្រប់រូបភាពឱ្យដល់ឫសគល់ និងការពង្រឹងការគៀរគរបន្ថែមនូវចំណូលមិនមែនសារពើពន្ធតាមបណ្តាក្រសួង ស្ថាប័ននានា។

### ក.១- ផ្នែកចំណូលពន្ធដារ

១២- វិធានការសម្រាប់អនុវត្តក្នុងឆ្នាំ ២០១៨ រួមមាន៖

- <u>បន្តពង្រឹងមុខងារប្រតិបត្តិការស្នូល ផ្តោតលើការចុះបញ្ជីអ្នកជាប់ពន្ធ, ការផ្តល់សេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម, ការស៊ើបអង្កេត, ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា</u> តាមរយៈ ៖
    - ការធ្វើបច្ចុប្បន្នកម្មបញ្ជីអ្នកជាប់ពន្ធឱ្យបានទៀងទាត់ និងទាន់ពេលវេលា ជាពិសេសបន្តការងារលុបសហគ្រាសដែលបាត់ខ្លួនចេញពីបញ្ជី,
    - ការពង្រឹងការចុះបញ្ជីពន្ធដារចំពោះសហគ្រាសដែលមិនទាន់បានចុះបញ្ជីពន្ធដារ ដែលរកឃើញដោយការធ្វើអង្កេតសហគ្រាស និងផ្ទៀងផ្ទាត់ព័ត៌មានជាមួយស្ថាប័នផ្សេងៗ,
    - ការផ្តល់សេវាជូនអ្នកជាប់ពន្ធធំចំនួន ១៥០ សហគ្រាស តាមរយៈសិក្ខាសាលា និងការពិគ្រោះយោបល់ ទាក់ទងនឹងប្រព័ន្ធពន្ធដារ និងរដ្ឋបាលសារពើពន្ធ,
    - ការរៀបចំការដាក់លិខិតប្រកាស និងការបង់ប្រាក់ Online ( E-Filing and E-Payment)
    - ការបន្តជំរុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យ ឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់ និងបន្ថយបន្ទុកសវនកម្ម,
    - ការពង្រឹងការធ្វើសវនកម្មលើវិស័យដែលមានសក្តានុពលមួយចំនួនដូចជាវិស័យនាំចេញ-នាំចូល វិស័យទេសចរណ៍ និងវិស័យសំណង់,
    - ការបន្តជ្រើសរើសសហគ្រាសដែលមានបុគ្គលសម្ព័ន្ធ (Group Companies) ជាអាទិភាពក្នុងការធ្វើសវនកម្ម ដោយសហការគ្នាជាក្រុម ដើម្បីរកឱ្យឃើញការគេចវេះពន្ធ និងការផ្ទេរថ្លៃ,
    - ការរៀបចំ និងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានស្តីពីការផ្ទេរថ្លៃ ( Transfer Pricing ) ដើម្បីទប់ស្កាត់ការគេចវេះពន្ធ,

- ការពង្រឹងការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការតឹងទារបំណុលពន្ធ ដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចជាការរឹបអូស ឬការឃុំគ្រងទ្រព្យសម្បត្តិរបស់អ្នកជំពាក់បំណុលពន្ធ និងការប្តឹងអ្នកជំពាក់បំណុលពន្ធទៅតុលាការ។

- បន្តការពង្រឹងមុខងារគាំទ្រ តាមរយៈ៖
  - ការរៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការអភិវឌ្ឍន៍ស្ថាប័ន,
  - ការពង្រឹងប្រព័ន្ធសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានឱ្យកាន់តែល្អប្រសើរ ដើម្បីឈានទៅការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការងារសវនកម្ម ប្រព័ន្ធផ្ទៀងផ្ទាត់អាករលើតម្លៃបន្ថែម (VAT Cross-Checking) និងប្រព័ន្ធគ្រប់គ្រងបំណុលពន្ធ,
  - ការបង្កើតប្រព័ន្ធគ្រប់គ្រងអ្នកប្រើប្រាស់រួមតែមួយ (Core System-Single sign-on)។

## ក.២- ផ្នែកចំណូលគយ និងរដ្ឋាករ

១៣- វិធានការសម្រាប់អនុវត្តក្នុងឆ្នាំ២០១៨ រួមមាន៖

- ការបន្តពង្រឹងការត្រួតពិនិត្យ និងបញ្ចេញទំនិញផ្តោតលើការប្រកាសគយ, ការកំណត់ និងធ្វើចំណាត់ថ្នាក់ហានិភ័យ និងសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ តាមរយៈ៖
  - ការបន្តលើកកម្ពស់អនុលោមភាព នៃការគ្រប់គ្រងចុះបញ្ជីទំនិញនាពេលនាំចូលមកដល់ដែនគយ ទាំងផ្លូវគោកនិងផ្លូវទឹក ព្រមទាំងការជំរុញឱ្យមានការជម្រះបញ្ជីពេញលេញជាមួយប្រតិវេទន៍គយ ដោយត្រូវផ្តោតជាសំខាន់លើទំនិញដែលមានវេទយិតភាពចំណូលខ្ពស់ ទំនិញកំណត់ពិសេសស្ថិតក្រោមប្រព័ន្ធអត្រាពន្ធគយ និងទំនិញក្រោមរបបគយឆ្លងកាត់ប្រទេសជាប់ព្រំដែនរួចចូលកម្ពុជាតាមផ្លូវគោក,
  - ការចុះឃ្លាំមើលនិងវាយតម្លៃឱ្យបានទៀងទាត់របស់ថ្នាក់ដឹកនាំគយ និងសវនករមានសមត្ថកិច្ចនូវប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានជាពិសេសការអនុវត្តនីតិវិធីត្រួតពិនិត្យគយតាមអង្គភាពគយមូលដ្ឋានពាក់ព័ន្ធនឹងការប្រមូលចំណូលគយ,
  - ការលើកកម្ពស់ការយល់ដឹងនិងការទទួលខុសត្រូវរបស់មន្ត្រីគយ និងធុរជនលើនីតិវិធីគយជាពិសេស កាតព្វកិច្ចនានាពាក់ព័ន្ធនឹងការប្រកាស, ការបង់ពន្ធ, ការដឹកជញ្ជូនចែកចាយ និងការកាន់រក្សាទំនិញវេទយិត,
  - ការបន្តលើកកម្ពស់គុណភាពប្រព័ន្ធគ្រប់គ្រងហានិភ័យគយ និងប្រព័ន្ធព័ត៌មានសម្រាប់ជាមូលដ្ឋានក្នុងការបង្ក្រាបឬអនុវត្តយន្តការសវនកម្មតាមគ្រប់រូបភាព ព្រមទាំងការអនុវត្តនូវនីតិវិធីតាមផ្លូវតុលាការ លើជនសង្ស័យឬជនល្មើសដែលមិនរាងចាល,
  - ការពង្រឹងប្រសិទ្ធភាពការងារត្រួតពិនិត្យរូបវន្តលើទំនិញនៅយន្តការដើមទី ដោយអង្គភាពគយមូលដ្ឋានមានសមត្ថកិច្ចទាំងថ្នាក់ការិយាល័យនិងថ្នាក់សាខាគយឱ្យមានអនុលោមភាពពេញលេញជាមួយនីតិវិធីត្រួតពិនិត្យ ជាពិសេសការលើកកម្ពស់ការទទួលខុសត្រូវរបស់មន្ត្រីត្រួតពិនិត្យរូបវន្តដោយភ្នែកទទេ និងតាមរយៈម៉ាស៊ីនស្កេន,

- ការដាក់ឱ្យអនុវត្តយន្តការផ្លាស់ប្តូរព័ត៌មានហានិភ័យផ្ទៃក្នុងគយ និងអន្តរស្ថាប័ន និងការលើកកម្ពស់ កិច្ចសហការអន្តរស្ថាប័នទប់ស្កាត់និងបង្ក្រាបបទល្មើសគយ ជាពិសេសបទល្មើសគយដាក់ស្តែងពាក់ព័ន្ធនឹងការនាំចេញ-នាំចូលទំនិញតាមមាត់ច្រកទ្វេភាគី ឬច្រករបៀងខុសច្បាប់,
- ការបន្តលើកទឹកចិត្តឱ្យមានការចូលរួមរបស់ធុរជនល្អក្នុងការងារបង្ក្រាបបទល្មើសគយ ក្រោមក្របខណ្ឌនៃយន្តការភាពជាដៃគូគយ និងវិស័យឯកជនតាមរូបភាពនៃការចូលរួម ផ្តល់ព័ត៌មាន ព្រមទាំងបទពិសោធន៍ល្អៗក្នុងតំបន់,
- ការបន្តពង្រឹងប្រសិទ្ធភាពយន្តការសវនកម្មគយតាមរយៈ ការលើកកម្ពស់សមត្ថភាពអង្គភាពសវនកម្ម ការពង្រីកភាពគ្របដណ្តប់នៃយន្តការនេះដល់គ្រប់វិស័យធុរកិច្ច និងការប្រើប្រាស់ទិន្នន័យហានិភ័យដែលប្រមូលបានពីប្រភពក្នុងនិងក្រៅប្រទេស,

- <u>ការបន្តការពង្រឹងយន្តការគាំទ្រ</u> តាមរយៈ៖
  - ការជំរុញអនុវត្តយន្តការសហការគយជាមួយស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ជាពិសេសជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីផ្ទៀងផ្ទាត់អនុលោមភាពពន្ធលើយានយន្តគ្រប់ប្រភេទនៅយន្តការកណ្តាលទី និងចុងទី ទាំងពេលនាំចូលសន្និធិ ពេលផ្គុំដំឡើង ពេលធ្វើផ្លាកលេខ និងពេលចរាចរចែកចាយតាមអាជីវកម្មដ្ឋាន ដោយផ្អែកលើប្រព័ន្ធទិន្នន័យ និងការកំណត់គម្សដ្ឋានច្បាស់លាស់ ទាំងយានយន្តឯកជន, យានយន្តរដ្ឋ ព្រមទាំងយានយន្តក្រោមរបបបណ្តោះអាសន្ន ផ្សេងៗ,
  - ការកសាង អនុវត្ត និងវាយតម្លៃការអនុវត្តផែនការសកម្មភាពឬគម្រោងលើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រង និងអភិវឌ្ឍអង្គភាពគយ ជាពិសេសលើ (១)-រចនាសម្ព័ន្ធគ្រប់គ្រង, (២)-សមត្ថភាពនិងសីលធម៌វិជ្ជាជីវៈមន្ត្រីគយ និង (៣)-ការបំពាក់មធ្យោបាយការងារ ទាំងមធ្យោបាយច្បាប់ និងមធ្យោបាយរូបវន្តផ្សេងទៀតឱ្យបានសមស្រប ដូចជា មធ្យោបាយប្រដេញនឹងប្រព័ន្ធទំនាក់ទំនងគមនាគមន៍ ព្រមទាំងការអនុវត្តប្រព័ន្ធលើកទឹកចិត្តមន្ត្រីគយមានស្នាដៃ និងដាក់ទណ្ឌកម្មមន្ត្រីគយអសកម្ម,
  - ការជំរុញពង្រឹងអនុលោមភាពអាជីវកម្មផលិតផលតេលសិលា និងថាមពលនាំចូលដោយបន្តផ្សព្វផ្សាយ និងអនុវត្តឱ្យបានកាន់តែពេញលេញតាមការកំណត់របស់រាជរដ្ឋាភិបាលជាធរមាន ពាក់ព័ន្ធនឹងការធ្វើអាជីវកម្មនាំចូល សន្និធិ និងចរាចរចែកចាយផលិតផលតេលសិលា ជាពិសេសការជំរុញអនុវត្តវិធានការបិទការនាំចូលផលិតផលតេលសិលាតាមផ្លូវគោក,
  - ការបន្តពង្រីកភាពគ្របដណ្តប់និងមុខងារប្រព័ន្ធស្វ័យប្រវត្តិកម្មគយនានា ជាពិសេសការកសាងប្រព័ន្ធតភ្ជាប់ដោយមធ្យោបាយអេឡិចត្រូនិករវាងប្រព័ន្ធតម្លៃគិតពន្ធគយ ប្រព័ន្ធគ្រប់គ្រងហានិភ័យ ប្រព័ន្ធស្ថិតិគយ ជាមួយប្រព័ន្ធស្វ័យប្រវត្តិកម្មគយផ្សេងទៀត ក៏ដូចជាជាមួយអគ្គនាយកដ្ឋានពន្ធដារ,

o ការបន្តវាយតម្លៃជាប្រចាំនូវផលប៉ះពាល់លើចំណូលគយពីបញ្ហាប្រឈមនានា និងការធ្វើវិចារណកម្ម និងពិពិធកម្មគោលនយោបាយគយនានាសំដៅប៉ះប៉ូវចំណូលគយ ដែលបាត់បង់ពីបញ្ហាប្រឈមនីមួយៗឱ្យបានសមស្របនិងទាន់ពេលវេលា ជាពិសេស (១)-ការបន្តពិនិត្យលទ្ធភាពដំឡើងអត្រាអាករពិសេស (២)-ការពង្រឹងសមត្ថភាពបង្ក្រាបបទល្មើស និងការកាត់បន្ថយការលើកទឹកចិត្តពន្ធអាករហួសពីការអនុវត្តល្អក្នុងតំបន់ និង (៣)-ការចាត់វិធានការមុតស្រួចនានាបន្ថែមទៀត ដើម្បីរក្សាចីរភាពកំណើនចំណូលគយតាមគោលនយោបាយរាជរដ្ឋាភិបាល។

## ក.៣- ផ្នែកចំណូលមិនមែនសារពើពន្ធ

១៤- វិធានការបន្តសម្រាប់អនុវត្តក្នុងឆ្នាំ២០១៧ រួមមាន៖

- បន្តសម្របសម្រួលដំណើរការរបស់គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ,
- បន្តសម្របសម្រួលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលតាមក្រសួង-ស្ថាប័នដែលទទួលខុសត្រូវក្នុងការតាមដាន កត់ត្រា កៀរគរចំណូល និងចាត់វិធានការតឹងទារបំណុល
- បន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង ការកត់ត្រា និងការផ្តល់របាយការណ៍ចំណូលមិនមែនសារពើពន្ធ ឱ្យកាន់តែមានតម្លាភាព និងទាន់ពេលវេលា ដោយពង្រឹងការគ្រប់គ្រងស្ថាប័ន, ការទទួលខុសត្រូវច្បាស់លាស់, ការដាក់ទណ្ឌកម្ម, សវនកម្ម និងអធិការកិច្ច តាមរយៈអនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូល មិនមែនសារពើពន្ធ ដែលនឹងត្រូវបញ្ចប់ក្នុងពេលឆាប់ៗ,
- បន្តរកមុខចំណូលថ្មីៗ និងពង្រឹងការប្រមូលមុខចំណូលដែលមានស្រាប់ ដែលមិនប៉ះពាល់ដល់ជីវភាពរបស់ប្រជាជនទូទៅ ក្នុងនោះរួមមានការបន្តស្វែងយល់ពីបទពិសោធន៍ពីប្រទេសដទៃទៀត,
- បន្តពង្រឹងយន្តការគណៈកម្មការអន្តរក្រសួង ដើម្បីទប់ស្កាត់មិនឱ្យមានបំណុលថ្មី និងការតឹងទារបំណុល,
- បន្តជំរុញការរៀបចំប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធតាមប្រព័ន្ធព័ត៌មានវិទ្យាកំពុងរៀបចំដោយក្រុមការងាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឈានទៅការបញ្ចប់ការរៀបចំប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ,
- បន្តជំរុញការប្រើប្រាស់ប្រព័ន្ធធនាគារ ក្នុងការបង់ចំណូលទៅគណនីទោលរបស់រតនាគារជាតិឱ្យគ្រប់ចំនួន និងទាន់ពេលវេលា,
- ស្នើអាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធរបស់ក្រសួងស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ,
- ជំរុញអនុវត្ត និងកែលម្អស្តង់ដារសេវាសម្រាប់បង់ចំណូល ឱ្យមានភាពងាយស្រួល និងតម្លាភាព,
- បន្តពង្រឹងការប្រមូលកម្រៃពីសេវាដឹកអ្នកដំណើរតាមអាកាស ដែលបច្ចុប្បន្នអគ្គនាយកដ្ឋានទ្រព្យរដ្ឋ និងចំណូលមិនមែនសារពើពន្ធកំពុងសហការជាមួយរដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍

ស៊ីវិល ដើម្បីបង្កើតកម្រៃ ៤ ដុល្លារអាមេរិក សម្រាប់អ្នកដំណើរក្នុងប្រទេស និង ៦ ដុល្លារអាមេរិក សម្រាប់អ្នកធ្វើដំណើរក្រៅប្រទេស,

- បន្តពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ច ដោយផ្អែកលើគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល,
- បន្តរៀបចំនិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តិ ដើម្បីកៀរគរចំណូលពីវិស័យកាស៊ីណូ និងឆ្នោតឡូតូ,
- បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងអាជីវកម្ម Online,
- ជំរុញការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរមណីយដ្ឋានសមាហរណល្បែងពាណិជ្ជកម្មឱ្យចេញនៅឆ្នាំ ២០១៨,
- បន្តកិច្ចសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីបង្ក្រាបអាជីវកម្មល្បែងខុសច្បាប់។

## ២.២.២- ក្របខណ្ឌចំណាយថវិកាឆ្នាំ២០១៨

១៥- គម្រោងចំណាយថវិកាឆ្នាំ ២០១៨ ត្រូវបានកំណត់ និងវិភាជ ដូចខាងក្រោម៖

- **ចំណាយសរុបថវិការដ្ឋ** សម្រាប់ឆ្នាំ២០១៨ ត្រូវបានគ្រោងស្មើនឹង ២៤,៦៨% នៃផ.ស.ស. គឺមានកំណើន ១,០៤ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១៥,៥% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ (ហៅកាត់ថា ច្បាប់ថវិកាឆ្នាំ ២០១៧)។ ក្នុងនោះ **ចំណាយចរន្តថវិការដ្ឋ**នឹងកម្រិតត្រឹម ១៥,៦៨% នៃផ.ស.ស. គឺមានកំណើន ០,២៦ ពិន្ទុភាគរយ នៃផ.ស.ស. ឬកើនឡើង ១២,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧ ដោយផ្តោតអាទិភាពជាពិសេសលើការបង្កើន **ចំណាយបៀវត្ស** សម្រាប់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធដែលនឹងធ្វើឱ្យចំណាយនេះឡើងដល់ ៥៣,៦៩% នៃ ចំណាយចរន្តសរុប ឬស្មើប្រមាណ ៨,៤២% នៃផ.ស.ស.។ **ចំណាយមូលធន** ត្រូវបានគ្រោងស្មើនឹង ៩,០០% នៃផ.ស.ស.គឺមានកំណើន ០,៧៨ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើនឡើង ២១,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧។ **ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងប្រទេស** ត្រូវបានគ្រោង ក្នុងកម្រិត ៣,៦៦% នៃផ.ស.ស. គឺមានកំណើន ០,៩៨ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ៥១,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧ និង**ចំណាយសម្រាប់ការទូទាត់ប្រាក់ខ្ចី** ត្រូវបានគ្រោងក្នុងកម្រិត ០,៧៤% នៃផ.ស.ស. កើនឡើង ១០,៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧។ ទន្ទឹមនេះ **ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស** ត្រូវបានគ្រោងក្នុងកម្រិត ៤,៥៩% នៃផ.ស.ស. គឺថយចុះ ០,២០ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើនឡើង ៦,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧។
- **ចំណាយចរន្តថវិកាថ្នាក់ជាតិ** ត្រូវបានវិភាជទៅតាមវិស័យនីមួយៗ លើមូលដ្ឋាននៃការបន្តខិតខំបង្កើនប្រសិទ្ធភាពចំណាយ (ទាំងប្រសិទ្ធភាពក្នុងការវិភាជ, ទាំងប្រសិទ្ធភាពក្នុងផ្នែកប្រតិបត្តិការ) ក្នុងវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច ក៏ដូចជាលើមូលដ្ឋាននៃការធានាឱ្យបាននូវកិច្ចដំណើរការដោយរលូន និងដោយជោគជ័យនៃការបោះឆ្នោតឆ្នាំ ២០១៨ ដូចខាងក្រោម៖
    - **វិស័យសង្គមកិច្ច** ត្រូវបានគ្រោងក្នុងកម្រិត ៥,៤៥% នៃផ.ស.ស គឺមានកំណើន ០,០៤ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១១.៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧,

- **វិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងក្នុងកម្រិត១,៤៩% នៃផ.ស.ស. គឺមានកំណើន ០,០៣ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១២,៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧,
- **វិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងក្នុងកម្រិត ២,១១% នៃផ.ស.ស គឺថយចុះ ០,១២ ពិន្ទុភាគរយនៃផ.ស.ស. ប៉ុន្តែមានកំណើន ៤,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧,
- **វិស័យការពារជាតិ សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងក្នុងកម្រិត ៣,៨៩% នៃផ.ស.ស គឺមានកំណើន ០,១៦ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១៥,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧។

- **ចំណាយចរន្តថវិការាជធានី ខេត្ត, មូលនិធិក្រុង ស្រុក ខណ្ឌ និង មូលនិធិឃុំ-សង្កាត់** ត្រូវកំណត់ត្រឹម ១,៤៧% នៃផ.ស.ស កើនឡើង ៤,៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧ ដែលក្នុងនោះថវិកាផ្ទាល់របស់ រាជធានី ខេត្ត សរុបមានប្រមាណ ០,៧២% នៃផ.ស.ស. និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់ រាជធានី ខេត្ត ស្មើនឹង ០,១៥% នៃផ.ស.ស., ថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់មូលនិធិក្រុង ស្រុក ខណ្ឌ ស្មើនឹង ០,១៦% នៃផ.ស.ស. ឬស្មើនឹង ១,០% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៧,និង ថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់មូលនិធិថវិកាឃុំ-សង្កាត់ឆ្នាំ ២០១៨ ស្មើនឹង០,៤៤% នៃផ.ស.ស. ឬស្មើនឹង ២,៨០% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៧។

## វិធានការដើម្បីបង្កើនប្រសិទ្ធភាពចំណាយ

១៦-ក្នុងក្របខណ្ឌនៃគោលដៅចំណាយខាងលើនេះ រាជរដ្ឋាភិបាលនឹងជំរុញការអនុវត្តយុទ្ធសាស្ត្រ និង ក្របខណ្ឌនៃវិធានការដើម្បី *បង្កើនប្រសិទ្ធភាពចំណាយ* ដូចខាងក្រោម៖

- បន្តការគិតគូរពីការរៀបចំថវិកាឱ្យកាន់តែមានលក្ខណៈផ្សារភ្ជាប់ទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល តាមរយៈការបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកាឈរលើមូលដ្ឋានចាំបាច់, ជាក់ស្តែង និងចំទិសដៅ ពិសេសការពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ស្របជាមួយនឹងការពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តថវិកា,
- ពង្រីកការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាឱ្យបានគ្រប់ក្រសួង-ស្ថាប័នទាំងថ្នាក់ជាតិពីចំនួន ៣៦ ក្រសួង-ស្ថាប័ន ក្នុងឆ្នាំ ២០១៧ ឱ្យឡើងដល់គ្រប់ក្រសួង-ស្ថាប័នទាំង ៣៩ ក្នុងឆ្នាំ ២០១៨, និង ពង្រីកការសាកល្បងនៅថ្នាក់ក្រោមជាតិ,
- បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធឱ្យទទួលបានច្រើនជាង ១ លានរៀល នៅឆ្នាំ ២០១៨ ក្នុងគោលដៅបង្កើនគុណភាព និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព, សមធម៌, សង្គតិភាព, ចីរភាពថវិកា និងស្ថិរភាពសេដ្ឋកិច្ច,
- បន្តរក្សាអាទិភាព និង វិចារណកម្មនៃគោលនយោបាយចំណាយនៅក្នុងវិស័យអប់រំ, បណ្តុះ-បណ្តាលវិជ្ជាជីវៈ, ប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីក, កសិកម្ម និងប្រព័ន្ធគាំពារសង្គម,
- បន្តធ្វើវិត្តារកម្មគោលនយោបាយចំណាយ (រួមជាមួយការបន្តរឹតត្បិតចំណាយមិនចាំបាច់) ក្នុងស្មារតីគាំទ្រដល់ "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម" និងគាំទ្រដល់ការទ្រទ្រង់ចីរភាពកំណើនសេដ្ឋកិច្ចសម្រាប់រយៈពេលមធ្យម និងវែង តាមរយៈការបង្កើនចំណាយវិនិយោគ

សាធារណៈលើការពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជា ផ្លូវថ្នល់, ផ្លូវដែក, កំពង់ផែ, ប្រព័ន្ធធារាសាស្ត្រស្រោចស្រព និងអគ្គីសនី។ល។ ដើម្បីផ្តល់ភាពងាយស្រួលដល់វិនិយោគិន, ពាណិជ្ជករ និងប្រជាជន។ បង្កើនការយកចិត្តទុកដាក់លើចំណាយថែទាំឱ្យមានប្រសិទ្ធភាព ក្នុងទិសដៅកែលម្អ និងពង្រឹងការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត,

- បន្តផ្តោតការយកចិត្តទុកដាក់ និងបង្កើនការវិនិយោគសាធារណៈឱ្យចំវិស័យដែលផ្តល់ផលិតភាពខ្ពស់ ក្នុងគោលដៅទ្រទ្រង់កំណើនប្រកបដោយចីរភាព ដូចជា វិស័យកសិកម្ម វិស័យចំណីអាហារ និងវិស័យ គាំទ្រដើម្បីជំរុញផលិតភាព, តម្លៃបន្ថែម និងជំរុញការកែច្នៃកសិផលសម្រាប់ការនាំចេញ, ការចិញ្ចឹមសត្វ និងវារីវប្បកម្ម តាមរយៈវិចារណកម្មគោលនយោបាយចំណាយក្នុងទិសដៅទទួលបានប្រសិទ្ធភាពខ្ពស់,
- បន្តជំរុញអនុវត្តកម្មវិធីសាច់ប្រាក់ពលកម្ម (Cash For Work) ដែលជាកម្មវិធីជួយស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ និងជាកម្មវិធីអន្តរាគមន៍ដោយត្រង់របស់រាជរដ្ឋាភិបាល ក្នុងការបង្កើតការងារនៅទីជនបទ ដែលគាំទ្រដល់វិស័យជំនាញ ទប់ស្កាត់ការធ្វើចំណាកស្រុក, បង្កើនផលិតភាព និងលើកកម្ពស់ជីវភាពប្រជាជន នៅទីជនបទ,
- លើកកម្ពស់ប្រសិទ្ធភាពនៃប្រតិបត្តិការចំណាយ តាមរយៈការបង្កើនតម្លៃនៃលុយ ដោយផ្តោតការយកចិត្តទុកដាក់លើភាពសមស្របនៃថ្លៃ, បរិមាណ, គុណភាព និងភាពទាន់ពេល នៃថវិកាដែលបានចំណាយ ទាំងចំណាយចរន្ត (ចំណាយបុគ្គលិក និងមិនមែនបុគ្គលិក) និងចំណាយមូលធន,
- បន្តពង្រឹងការគ្រប់គ្រងចំណាយសាធារណៈ ជាពិសេសបន្តពង្រឹង និងជំរុញការកែលម្អការអនុវត្តថវិកា តាមរយៈការបន្តកាត់បន្ថយនីតិវិធីចំណាយ, ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់, ការបន្តពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស, ការបន្តត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងឆមាស, ការបន្តពង្រឹងការត្រួតពិនិត្យផ្ទៃក្នុងដើម្បីបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកាដែលសម្រេចបាន និងបន្តបង្កើនប្រសិទ្ធភាពគណនេយ្យភាពហិរញ្ញវត្ថុ និងជំហានបន្ទាប់ផ្សេងៗទៀត,
- គិតគូរឱ្យមានកញ្ចប់ថវិកាត្រៀមបម្រុងសម្រាប់ដោះស្រាយតម្រូវការបន្ទាន់,ករណីតម្រូវការចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាល, វិបត្តិផ្សេងៗ និងប្រជានស័ក្តិ,
- លើកកម្ពស់ប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន ទាំងពីប្រភពថវិការដ្ឋ ប្រភពហិរញ្ញប្បទានក្រៅប្រទេស និងពីប្រភពថវិការបស់ដៃគូឯកជនតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន តាមរយៈ៖
    - ការរៀបចំក្របខណ្ឌ និងគោលការណ៍រួមសម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈ ពីគ្រប់ប្រភពហិរញ្ញប្បទាន ដែលគ្រោងនឹងដាក់ឱ្យអនុវត្តដោយអនុក្រឹត្យនៅមុនដំណាច់ឆ្នាំ២០១៧,

- ការរៀបចំគោលការណ៍ និងនីតិវិធីលម្អិតសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានពីប្រភពថវិកាជាតិ ដែលគ្រោងដាក់ឱ្យអនុវត្តដោយអនុក្រឹត្យ នៅក្នុងឆ្នាំ២០១៨,
- ការពិនិត្យ និងធ្វើបច្ចុប្បន្នកម្មលើនីតិវិធីរួមសម្រាប់គ្រប់គ្រង និងអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តដោយអនុក្រឹត្យនៅក្នុង ឆ្នាំ២០១៨,
- ការរៀបចំក្របខណ្ឌគតិយុត្ត យន្តការស្ថាប័ន និងនីតិវិធីប្រតិបត្តិការរួមសម្រាប់គ្រប់គ្រងការរៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូ រវាងរដ្ឋ និងវិស័យឯកជន ដែលគ្រោងនឹងដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៨;

- បន្តអនុវត្តក្របខណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុល និងបន្តពង្រឹងបន្ថែមសមត្ថភាព ស្ថាប័ន ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ក្នុងគោលដៅបន្តរក្សាចីរភាពនៃការគ្រប់គ្រងបំណុល។

### ២.២.៣-ក្របខណ្ឌតុល្យភាពថវិកាឆ្នាំ២០១៨

១៧- ជារួម ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការផ្នែកចំណូល និង ផ្នែកចំណាយខាងលើ នឹងជួយសម្រេចបាននូវអតិរេកថវិកាចរន្តស្មើនឹងប្រមាណ ២,៩២% នៃ ផ.ស.ស. និងឱនភាពថវិកាសរុបក្នុងរង្វង់ ៥,៩០% នៃផ.ស.ស. នៅក្នុងឆ្នាំ២០១៨។ ដូច្នេះ ដើម្បីធានាបាននូវតុល្យភាពថវិកា រាជរដ្ឋាភិបាលគ្រោងនឹងប្រើប្រាស់ប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាលចំនួនប្រមាណ១,០% នៃផ.ស.ស ត្រូវជាប្រមាណ ៩៩៤ ៧៣៧ លានរៀល។ ប្រការនេះ នឹងផ្តល់លទ្ធភាពដល់រាជរដ្ឋាភិបាលក្នុងការបន្តគាំទ្រគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់ការធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព, ការបន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើនភាពទាក់ទាញ និងភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា និងការដំឡើងបៀវត្សមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ តាមផែនការដែលបានគ្រោងទុក ទន្ទឹមនឹងការបន្តធានារក្សាបាននូវលំហថវិកាក្នុងទំហំមួយសមស្របសម្រាប់ត្រៀមទប់ទល់នឹងវិបត្តិ ក៏ដូចជាហានិភ័យនានាដែលអាចកើតមានឡើងជាយថាហេតុ។

## ៣. គោលការណ៍ និងបច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០១៨

### ៣.១- ការគ្រោងចំណូលថវិកាឆ្នាំ២០១៨

១៨- ការគ្រោងគិតចំណូលថវិកាចរន្ត អាស្រ័យលើប្រភពធនធាននៃផលិតផល ឬផលទុន ដែលជាប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងល័ក្ខខ័ណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ៖

- ចំណូលសារពើពន្ធ ត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖
  - លទ្ធផលដែលសម្រេចនៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ (ឆ្នាំ២០១៧),
  - ចំណូលបន្ថែមដែលសង្ឃឹមថានឹងប្រមូលបាន ដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ គោលនយោបាយគយនិងរដ្ឋាករ ការធ្វើវិចារណកម្មសារពើពន្ធ និងការប្រមូលបំណុលពន្ធដែលត្រូវទារ,

- ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ច និងអាជីវកម្មនៅពេលខាងមុខ
- ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើអត្រា និងមូលដ្ឋានប្រមូលពន្ធ

• ចំពោះចំណូលមិនមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឱ្យមានផលទុន ដូចជាកិច្ចសន្យាសម្បទានគ្រប់ប្រភេទ កិច្ចសន្យាជួលសេវាកម្ម ការពង្រឹងនិងកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម។ល។

## ៣.២- ការគ្រោងចំណាយថវិកាឆ្នាំ២០១៨

១៩- **ក្រសួង-ស្ថាប័ន** មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ដែលបាននិងកំពុង**អនុវត្តថវិកាកម្មវិធី** និង ក្រសួង-ស្ថាប័នដែលត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីក្នុងឆ្នាំ២០១៨ ត្រូវបន្ត និងយកចិត្តទុកដាក់លើប្រសិទ្ធភាពនៃការគ្រោងថវិកាទៅតាមកម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាព និង ជាពិសេសត្រូវផ្តោតការយកចិត្តទុកដាក់លើការកំណត់លទ្ធផល ឬធាតុចេញ (Output) ដែលនឹងសម្រេចបាន។ ប្រការនេះ គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ការរៀបចំថវិកា និងការពិភាក្សាចរចាថវិកា ព្រមទាំងជាមូលដ្ឋានសម្រាប់ធ្វើវិមជ្ឈការសិទ្ធិអំណាចនៃការអនុវត្តចំណាយផងដែរ។ លើសពីនេះ ក្រសួង-ស្ថាប័ន ដែលមានបទពិសោធន៍ក្នុងការរៀបចំ ក៏ដូចជាក្នុងការអនុវត្តថវិកាកម្មវិធីរួចហើយ ត្រូវកែលម្អរចនាសម្ព័ន្ធកម្មវិធី និងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនឱ្យកាន់តែល្អប្រសើរ និងស៊ីសង្វាក់គ្នា ដើម្បីសម្រួលដល់ការអនុវត្តឱ្យកាន់តែរលូនល្អ ហើយឈានទៅសម្រេចបានលទ្ធផលល្អ និងមានការទទួលខុសត្រូវកាន់តែច្បាស់លាស់។ *សូមរៀបចំគម្រោងថវិកាតាមតារាងគំរូដែលភ្ជាប់មកជាមួយសារាចរណែនាំនេះ។*

២០- គ្រប់**ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត** ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ត្រូវរៀបចំគម្រោងចំណាយដែលឆ្លុះបញ្ចាំងយ៉ាងលម្អិតទៅតាមមាតិកាសេដ្ឋកិច្ចនៃចំណាត់ថ្នាក់ថវិកា (ជំពូក គណនី និងអនុគណនី) ព្រមទាំងត្រូវវិភាគឱ្យបានច្បាស់លាស់អំពីតម្រូវការចំណាយតាមចង្កោមសកម្មភាព អនុកម្មវិធី និងកម្មវិធី និងត្រូវភ្ជាប់មកជាមួយនូវឯកសារសម្រាប់គាំទ្រ រួមទាំងឯកសារអង្កេត ឬវិភាគតាមការចាំបាច់ ព្រមទាំងពន្យល់បញ្ជាក់អំពីភាពចាំបាច់នៃតម្រូវការចំណាយលើសកម្មភាពការងារនីមួយៗឱ្យបានគ្រប់ជ្រុងជ្រោយ ហើយឯកសារទាំងនេះ ក៏ជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យ ពិភាក្សា និង ចរចាថវិកាផងដែរ។ លើសពីនេះ ការគណនាតម្រូវការចំណាយត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជា ចំណាយបន្ទុកបុគ្គលិក និងចំណាយមិនមែនបន្ទុកបុគ្គលិក ដែលត្រូវប៉ាន់ស្មានតម្លៃជាតុចូលដែលត្រូវការជាក់ស្តែង ដោយធៀបនឹងតម្រូវការប្រើប្រាស់ក្នុងឆ្នាំ ២០១៦ និងការប៉ាន់ស្មាននៃការអនុវត្តក្នុងឆ្នាំ ២០១៧ និងដោយផ្អែកលើថ្លៃឯកតាជាក់ស្តែងនៃទីផ្សារ ឬតាមគោលបបកំណត់ជាដើម។

២១- ឈរលើមូលដ្ឋានតម្រូវការចំណាយ ដែលបានប៉ាន់ស្មាននៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ២០១៨-២០២០, ក្នុងការរៀបចំគម្រោងចំណាយថវិកាឆ្នាំ ២០១៨ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ត្រូវជានាឱ្យបាននូវការគ្រោងចំណាយរបស់ខ្លួន ដោយអនុលោមទៅតាម **គោលការណ៍** និង **បណ្តាវិធានការ** ដូចខាងក្រោម៖

**ក-ចំណាយបន្ទុកបុគ្គលិក(ជំពូក៦៤)៖** នាយកដ្ឋានបុគ្គលិកដែលជាសេនាធិការរបស់ក្រសួង-ស្ថាប័ននីមួយៗ ត្រូវសម្របសម្រួលនិងគ្រោងចំណាយបន្ទុកបុគ្គលិកឱ្យបានសុក្រឹតទៅតាមគោលការណ៍នៃ

ការដំឡើងបៀវត្សរបស់រាជរដ្ឋាភិបាល ព្រមជាមួយនឹងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា គឺចៀសវាងការគ្រោងបៀវត្ស ឬ បន្ទុកពាក់ព័ន្ធនឹងបុគ្គលិកនេះទុកចោលមិនប្រើប្រាស់ដូចឆ្នាំកន្លងមក។ គោលការណ៍សម្រាប់ការគ្រោងបន្ទុកបុគ្គលិកឆ្នាំ២០១៨ រួមមាន៖

- ត្រូវគ្រោងតាមមូលដ្ឋាននៃក្របខណ្ឌ និងកម្រិតបៀវត្សឆ្នាំ ២០១៧ គឺតាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រសួងមុខងារសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ២០១៧ ដោយ**ដំឡើងបៀវត្សមូលដ្ឋាន** តាមតម្លៃឯកតាសន្ទស្សន៍ ២ ១៣០ រៀល ដោយគិតចាប់ពីខែ មករា ដល់ ខែធ្នូ គឺមានកំណើនស្មើនឹង ១២% ក្នុងមួយឆ្នាំ,
- **ចំនួនក្របខណ្ឌថ្មី** ត្រូវគ្រោងយ៉ាងច្រើន ស្មើនឹងចំនួនមន្ត្រីចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណភាព ដែលត្រូវកាត់ចេញពីអង្គភាពសាមី ហើយត្រូវបញ្ជាក់ពីគោលដៅនៃតម្រូវការ និងមុខងារនៃមន្ត្រីដែលត្រូវជ្រើសរើសបន្ថែមនេះ។ *ក្នុងករណីការជ្រើសរើសមន្ត្រីក្របខណ្ឌថ្មី ដែលមានចំនួនតិចជាងចំនួនមន្ត្រីចូលនិវត្តន៍នោះ ក្រសួង-ស្ថាប័ន អាចស្នើប្រើប្រាស់ថវិកានោះ សម្រាប់បន្ថែមចំណាយមិនមែនបន្ទុកបុគ្គលិក ដើម្បីជាប្រយោជន៍សម្រាប់អង្គភាពរបស់ខ្លួន។*
- ការដំឡើង**ប្រាក់បំណាច់មុខងារ**ជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ នឹងត្រូវបានអនុវត្តគិតចាប់ពីខែ មេសា ដល់ ខែ ធ្នូ ឆ្នាំ ២០១៨ ទៅតាមកម្រិតនៃប្រាក់បំណាច់មុខងារដូចតទៅ៖
  - **សម្រាប់មន្ត្រីរាជការដែលបម្រើការងារក្នុងក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទ នៃវិស័យរដ្ឋបាល, ការទូត, បច្ចេកទេស និងផ្សេងៗ៖**
    - ផ្តល់បន្ថែម ១០០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារចាប់ពី ៣៥០ ០០០ រៀល ទៅដល់កម្រិតក្រោម ៥០០ ០០០ រៀល
    - ផ្តល់បន្ថែម ៤០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារចាប់ពី ៥០០ ០០០ រៀល ឡើងទៅ។
  - **សម្រាប់មន្ត្រីរាជការដែលបម្រើការងារក្នុងក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទ នៃវិស័យអប់រំ៖**
    - ផ្តល់បន្ថែម ១០០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារចាប់ពី ៤៥០ ០០០ រៀល ទៅដល់កម្រិតក្រោម ៥៤០ ០០០ រៀល,
    - ផ្តល់បន្ថែម ៩០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារចាប់ពី ៥៤០ ០០០ រៀល ទៅដល់កម្រិតក្រោម ៧៥០ ០០០ រៀល,
    - ផ្តល់បន្ថែម ៤០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារចាប់ពី ៧៥០ ០០០ រៀល ឡើងទៅ។
  - **សម្រាប់មន្ត្រីរាជការដែលបម្រើការងារក្នុងក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទ នៃវិស័យសុខាភិបាល៖**

- ផ្តល់បន្ថែម ១០០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៤៥០ ០០០ រៀល ទៅដល់កម្រិតក្រោម ៥៩០ ០០០ រៀល,
- ផ្តល់បន្ថែម ៩០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៥៩០ ០០០ រៀល ទៅដល់កម្រិតក្រោម ៧០០ ០០០ រៀល,
- ផ្តល់បន្ថែម ៤០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៧០០ ០០០ រៀល ឡើងទៅ។

▪ **សម្រាប់យោធិន៖**

- ផ្តល់បន្ថែម ១០០ ០០០ រៀល សម្រាប់យោធិនដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ២៥០ ០០០ រៀល ទៅដល់កម្រិតក្រោម ៥០០ ០០០ រៀល,
- ផ្តល់បន្ថែម ៨០ ០០០ រៀល សម្រាប់យោធិនដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៥០០ ០០០ រៀល ទៅដល់កម្រិតក្រោម ៦៥០ ០០០ រៀល,
- ផ្តល់បន្ថែម ៦០ ០០០ រៀល សម្រាប់យោធិនដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៦៥០ ០០០ រៀល ទៅដល់កម្រិតក្រោម ១ ៣៤០ ០០០ រៀល,
- ផ្តល់បន្ថែម ៤០ ០០០ រៀល សម្រាប់យោធិនដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ១ ៣៤០ ០០០ រៀល ឡើងទៅ។

▪ **សម្រាប់នគរបាលជាតិ និងអនុរក្សពន្ធនាគារ៖**

- ផ្តល់បន្ថែម ១០០ ០០០ រៀល សម្រាប់នគរបាលជាតិ និងអនុរក្សពន្ធនាគារដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ២៥០ ០០០ រៀល ទៅដល់កម្រិតក្រោម ៥០០ ០០០ រៀល,
- ផ្តល់បន្ថែម ៨០ ០០០ រៀល សម្រាប់នគរបាលជាតិ និងអនុរក្សពន្ធនាគារដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៥០០ ០០០ រៀល ទៅដល់កម្រិតក្រោម ៦៥០ ០០០ រៀល,
- ផ្តល់បន្ថែម ៦០ ០០០ រៀល សម្រាប់នគរបាលជាតិ និងអនុរក្សពន្ធនាគារដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៦៥០ ០០០ រៀល ទៅដល់កម្រិតក្រោម ១ ៤៤០ ០០០ រៀល,
- ផ្តល់បន្ថែម ៤០ ០០០ រៀល សម្រាប់នគរបាលជាតិ និងអនុរក្សពន្ធនាគារដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ១ ៤៤០ ០០០ រៀល ឡើងទៅ។

• ចំនួនមន្ត្រីជាប់កិច្ចសន្យា ត្រូវគ្រោងមិនឱ្យលើសចំនួនដែលក្រសួងមុខងារសាធារណៈផ្តល់ជូន ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវប្រើប្រាស់ប្រកបដោយតម្លាភាព និងការទទួលខុសត្រូវ ស្របតាមគោលការណ៍ ដែលមានចែងក្នុងអនុក្រឹតលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា។ ចំពោះប្រាក់ឧបត្ថម្ភប្រចាំខែ សម្រាប់មន្ត្រីជាប់កិច្ចសន្យា ត្រូវគ្រោងដំឡើងពី ៥០០ ០០០ រៀល ក្នុងឆ្នាំ ២០១៧ ទៅដល់ ៦០០ ០០០ រៀល សម្រាប់រយៈពេល ១២ ខែ ដោយគ្រោងអនុវត្តចាប់ពីខែ មករា ដល់ ខែធ្នូ ឆ្នាំ ២០១៨។

• ជាមួយគ្នានេះដែរ របបសន្តិសុខសង្គមអប្បបរមាប្រចាំខែ ត្រូវគ្រោងដំឡើងពី ៤២០ ០០០ រៀល ក្នុងឆ្នាំ ២០១៧ ទៅដល់ ៤៨០ ០០០ រៀល។ និវត្តជនដែលជាអតីតមន្ត្រីរាជការ

ស៊ីវិល និងអតីតយុទ្ធជន ត្រូវគ្រោងផ្តល់បន្ថែម ៤០ ០០០ រៀល និង ២០ ០០០ រៀល ដោយផ្អែកលើកម្រិតរបបសន្តិសុខសង្គមប្រចាំខែ ដោយគ្រោងអនុវត្តចាប់ពីខែ មេសា ឆ្នាំ ២០១៨ ។

**ខ- ចំណាយក្រៅបន្ទុកបុគ្គលិក (ជំពូក៦០ ការទិញ, ជំពូក៦១ សេវាកម្ម, ជំពូក៦២ អត្ថប្រយោជន៍សង្គម, ជំពូក៦៥ ឧបត្ថម្ភធន)** ជាសរុបសម្រាប់ឆ្នាំ២០១៨ ត្រូវគ្រោងក្នុងកម្រិតអតិបរមាត្រឹមកញ្ចប់ឥណទាននៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ព្រោះអាទិភាពចំណាយឆ្នាំ២០១៨ ត្រូវបានបញ្ជាក់ច្បាស់លាស់ក្នុងក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺ "ថវិកាឆ្នាំ២០១៨ ត្រូវផ្តោតជាសំខាន់លើការដំឡើងបៀវត្ស និងការវិនិយោគដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច"។*ក្នុងន័យនេះ ក៏មិនមែនមានន័យថា កញ្ចប់ថវិកាឆ្នាំ ២០១៨ នឹងទទួលបានស្មើឆ្នាំ២០១៧ ដោយស្វ័យប្រវត្តិនោះដែរ* គឺត្រូវទាមទារឱ្យក្រសួង-ស្ថាប័ននីមួយៗ បង្កើនប្រសិទ្ធភាពនៃការធ្វើអាទិភាវូបនីយកម្មមុខចំណាយផង និងប្រសិទ្ធភាពប្រតិបត្តិការចំណាយផង។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័ន ដែលមានសមិទ្ធិកម្មល្អលើការងារកែទម្រង់ដែលទទួលស្គាល់ជាសាធារណៈ នឹងត្រូវទទួលបានការលើកទឹកចិត្ត។ ដូច្នេះ *គ្រប់ក្រសួង-ស្ថាប័ន ត្រូវធ្វើអាទិភាវូបនីយកម្មនៃអាទិភាពគោលនយោបាយ និងថ្លឹងថ្លែងបែងចែកថវិការវាងកម្មវិធីនីមួយៗ ជាពិសេសកម្មវិធីស្នូលរបស់ក្រសួង-ស្ថាប័ន ដើម្បីសម្រេចគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។ ក្រសួង-ស្ថាប័នត្រូវពិនិត្យលទ្ធភាពនៃការផ្ទេរធនធានថវិកាពីកម្មវិធីមួយ ទៅកម្មវិធីមួយទៀត ឬ ពីអង្គភាពថវិកាមួយ ទៅអង្គភាពថវិកាមួយទៀត នៅក្នុងក្រសួង-ស្ថាប័នតែមួយឱ្យអស់លទ្ធភាព ព្រមជាមួយនឹងការថ្លឹងថ្លែងតុល្យភាពនៃការបែងចែកធនធាន និងសិទ្ធិអំណាច ទៅតាមនិងរវាងអង្គភាពថវិកានីមួយៗក្នុងក្របខណ្ឌពិដានកញ្ចប់ថវិកាដែលបានកំណត់ និងត្រូវចៀសវាងការបំប៉ោងចំណាយដោយមូលហេតុនៃការអនុវត្តថវិកាកម្មវិធី។* ក្នុងន័យនេះដែរ ចំណាយក្រៅបន្ទុកបុគ្គលិក ត្រូវគ្រោងដោយឈរលើគោលការណ៍ ដូចខាងក្រោម៖

- **ការបន្តអនុវត្តសកម្មភាពការងារកំពុងដំណើរការ** ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវគ្រោងចំណាយនៃកម្មវិធីនីមួយៗ ដោយផ្អែកលើបរិមាណធាតុចូល ដែលធ្លាប់ប្រើក្នុងឆ្នាំ២០១៦ កន្លងទៅ និងការប៉ាន់ស្មានអនុវត្តនៅក្នុងឆ្នាំ ២០១៧ នេះ និង ដោយផ្អែកលើតម្លៃឯកតាជាក់ស្តែងលើទីផ្សារ ហើយចៀសវាងការបង្កើនបរិមាណធាតុចូល លើសពីតម្រូវការដែលធ្លាប់មាន។ ទន្ទឹមនេះ ត្រូវគ្រោងថវិកាប្រកបដោយលក្ខណៈត្បិតត្បៀត និងសន្សំសំចៃខ្ពស់ ពិសេសលើមុខសញ្ញាទិញឧបករណ៍ សម្ភារបរិក្ខារទំនើប គ្រឿងសង្ហារឹមប្រណិត ការបោះពុម្ពប្រណិត សម្ភារការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវអធឹកអធម បេសកកម្មក្នុង និងក្រៅប្រទេស ព្រមទាំងសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជា សេវាទូរគមនាគមន៍ អគ្គិសនី និងទឹក ជាដើម។ លើសពីនេះ ត្រូវលុបបំបាត់ការខ្ជះខ្ជាយចំណាយ ឬបំប៉ោងចំណាយ លើការរៀបចំកិច្ចប្រជុំ សិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ ការតាំងពិពណ៌។ ដោយឡែកកិច្ចប្រជុំពាក់ព័ន្ធនឹងអាស៊ាន គឺអនុញ្ញាតសម្រាប់តែកិច្ចប្រជុំដែលត្រូវវេន ចំពោះកិច្ចប្រជុំដែលមិនចំវេន គឺត្រូវសុំគោលការណ៍អនុញ្ញាតពីប្រមុខរាជរដ្ឋាភិបាល។ ចំពោះកិច្ចប្រជុំ ឬសិក្ខាសាលា ដែលគ្រោងក្នុងថវិកា ត្រូវបង្ហាញពីភាពចាំបាច់ ភាពសមរម្យនៃការរៀបចំទាំងក្នុងទំហំ និងតម្លៃ។

- ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវពិនិត្យឡើងវិញ និងត្រូវកាត់ចេញនូវមុខចំណាយទាំងឡាយណាដែលមានតម្រូវការសម្រាប់តែអនុវត្តនៅក្នុងឆ្នាំ ២០១៧ ហើយលែងត្រូវការនៅក្នុងឆ្នាំ២០១៨ ឬសកម្មភាពការងារ ដែលនឹងត្រូវបញ្ចប់នៅក្នុងឆ្នាំ២០១៧,
- **ថវិកាដែលកាត់ចេញពីមុខចំណាយ ឬសកម្មភាពការងារដែលត្រូវបានបញ្ចប់ មិនមែនជាកម្មវត្ថុនៃការវិភាជឡើងវិញជាស្វ័យប្រវត្តិនោះឡើយ គឺមានន័យថាលុះត្រាតែមានសកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយថ្មី** ដែលត្រូវអនុវត្ត ហើយដែលត្រូវបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ និងមានយុត្តិការអំពីភាពចាំបាច់ និងបន្ទាន់ ដោយត្រូវផ្តល់ការពន្យល់ និងផ្តល់អំណះអំណាងឱ្យបានត្រឹមត្រូវ និងច្បាស់លាស់សម្រាប់សកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយថ្មី ហើយត្រូវភ្ជាប់មកជាមួយនូវគម្រោងចំណាយលម្អិតច្បាស់លាស់ ទើបអាចចាត់ទុកជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យ ពិភាក្សា និងចរចា។
- ការគ្រោង និងវិភាជថវិកា ត្រូវបង្កើនវិមជ្ឈការការផ្ទេរចំណាយរដ្ឋបាលជាប្រចាំ និង សោហ៊ុយបេសកកម្មក្នុង និងក្រៅប្រទេសជាដើម ទៅតាមអង្គភាពថវិកាឱ្យបានច្រើនក្នុងកម្រិតអតិបរមា។
- ចំពោះតម្រូវការចំណាយបន្ថែមលើសពីពិដានកញ្ចប់ថវិកា ត្រូវឆ្លងការចរចាកម្រិតថ្នាក់ដឹកនាំក្រសួង ឬក្នុងករណីចាំបាច់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងស្នើសុំការសម្រេច ឬស្នើសុំការសម្រេចឡើងវិញពីប្រមុខរាជរដ្ឋាភិបាល បន្ទាប់ពីមានឯកសារទស្សនាទាន យុត្តិការស្តីពីគោលនយោបាយ និងកម្មវិធី ឬមុខសញ្ញាចំណាយ និងតម្លៃច្បាស់លាស់។ *សម្រាប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានការកិច្ចប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំដាក់ចេញវិធានការដាក់ស្តែងបន្ថែម សម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ព្រោះលទ្ធផល និងការបង្ហាញពីកិច្ចខិតខំក្នុងការប្រមូលចំណូល គឺជាកម្មវត្ថុនៃការរឹតត្បិត ឬការលើកទឹកចិត្តចំណាយ នៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ។*

**គ. ចំណាយមូលធន/វិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាជាតិ (ជំពូក២១)** ត្រូវអនុវត្តតាមក្របខណ្ឌនៃការវិភាជដោយឡែក ដោយអនុលោមតាមអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល។ សម្រាប់ក្រសួង-ស្ថាប័នដែលត្រូវទទួលបានការវិភាជថវិកាជាទៀងទាត់ ទំហំថវិកានឹងត្រូវបានវិភាជស្របតាមគោល-នយោបាយ ស្របជាមួយនឹងដំណើរការនៃការរៀបចំច្បាប់ថវិកាប្រចាំឆ្នាំ។ ចំពោះគម្រោងអាទិភាពលម្អិត គឺជាកម្មវត្ថុនៃកិច្ចពិភាក្សាក្រោមយន្តការអន្តរក្រសួងដែលមានស្រាប់ ឬដែលនឹងត្រូវបង្កើតឡើង។ ដោយឡែកសម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀតដែលជាកម្មវត្ថុទទួលបានថវិកាពីកញ្ចប់ឥណទានមិនទាន់បែងចែក ត្រូវសិក្សា និងលើកគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ និងរៀបចំអាទិភាពការូបនីយកម្មគម្រោង ស្នើសុំការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាល ទៅតាមលទ្ធភាពថវិកា។

ទន្ទឹមនេះ គម្រោងវិនិយោគដែលអាចស្នើឡើងដើម្បីពិភាក្សា ត្រូវបំពេញតាមលក្ខខ័ណ្ឌ ដូចខាងក្រោម៖

- ត្រូវតែជាគម្រោងដែលមានក្នុងក្របខណ្ឌគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងរបស់ក្រសួង-ស្ថាប័នសាមី,
- ជាគម្រោងដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់,
- ជាគម្រោងដែលមានផលប៉ះពាល់តិចតួចដល់បរិស្ថាន និងសង្គម,
- ចំពោះគម្រោងធំៗ ត្រូវមានការសិក្សាសមិទ្ធិច្បាស់លាស់។

២២- ក្នុងគោលបំណងផ្តល់ភាពទន់ភ្លន់ចំពោះក្រសួង-ស្ថាប័ន និងមន្ទីរជំនាញ ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្នុងការរៀបចំថវិកា ជាពិសេសដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងសម្រាប់អនុវត្តសកម្មភាពការងារថ្មី ការកំណត់កញ្ចប់ថវិកាអតិបរមាតាមបណ្តាជំពូកខាងលើ ដោយផ្អែកលើមូលដ្ឋាននៃឥណទានថវិកាឆ្នាំ២០១៧ អាចត្រូវបានអនុញ្ញាតឱ្យធ្វើការកែសម្រួលតាមតម្រូវការជាក់ស្តែង ដោយរក្សាកញ្ចប់សរុបនៃឥណទានថវិកាក្រៅពីបន្ទុកបុគ្គលិកទាំងអស់យ៉ាងច្រើនត្រឹមកម្រិតឆ្នាំ២០១៧។ ប៉ុន្តែ ការរៀបចំគម្រោងចំណាយលម្អិតតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់ដើម្បីបង្កើនសុក្រឹតភាពនៃការគ្រោង និងវិភាជថវិកា ព្រោះ *ដូចជាឆ្នាំមុនៗដែរ ការធ្វើនិយ័តភាពឥណទានថវិកាផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត អាចនឹងត្រូវអនុញ្ញាតឱ្យធ្វើបានទាល់តែចាប់ពីត្រីមាសទី២ សម្រាប់ក្រសួង-ស្ថាប័នអនុវត្តថវិកាកម្មវិធីទាំងអស់* ហើយត្រូវផ្អែកលើហេតុផល និងលទ្ធផលការងារដែលសម្រេចបាន។

២៣- ទន្ទឹមនឹងការគ្រោងចំណាយដោយផ្អែកលើគោលការណ៍នៃការកំណត់កញ្ចប់ និងវិធានការខាងលើ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវធ្វើការ**គណនាតម្រូវការចំណាយនៃជំពូកក្រៅពីបន្ទុកបុគ្គលិក** រួមមាន ជំពូក៦០ ជំពូក៦១ ជំពូក៦២ ជំពូក៦៣ និងជំពូក៦៥ ដោយផ្អែកលើមូលដ្ឋានពីរបន្ថែមទៀត ដូចខាងក្រោម៖

- *កំណត់ចំណាយជាប្រចាំ ហើយបង្កើតមូលដ្ឋានគណនាតម្រូវការចំណាយនេះ ឱ្យបានច្បាស់លាស់*។ ចំណាយជាប្រចាំ គឺជាចំណាយដែលមានតម្រូវការជាប្រចាំ និងត្រូវការចំណាយជារៀងរាល់ឆ្នាំ ដែលរួមមាន ការចំណាយសម្ភារផ្គត់ផ្គង់ និង ថែទាំជាប្រចាំ (ដូចជាសម្ភារផ្គត់ផ្គង់ ថែទាំតូចតាចសម្រាប់ថែទាំអគារ ប្រាសាទ ផ្លូវថ្នល់ ស្ពាន លូ រថយន្ត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ) និងសម្ភារផ្គត់ផ្គង់រដ្ឋបាលជាប្រចាំ (ដូចជា សម្ភារការិយាល័យ ការបោះពុម្ពការទិញឯកសារ សម្ភារបរិក្ខារប្រើប្រាស់ជាប្រចាំ ស្បៀងអាហារ និងឯកសណ្ឋាន សម្រាប់ក្រសួង-ស្ថាប័នមួយចំនួនដែលត្រូវការប្រើប្រាស់ជាប្រចាំ ព្រមទាំងការចំណាយលើ អគ្គិសនី ទឹក ប្រេងឥន្ធនៈ និងទូរស័ព្ទជាដើម)។ ប្រភេទចំណាយជាប្រចាំនេះ គួរកំណត់ឱ្យបានច្បាស់លាស់ និងបង្កើតមូលដ្ឋានគណនាឱ្យបានត្រឹមត្រូវ និងសមស្របទៅតាមតម្រូវការជាក់ស្តែង ព្រមទាំង**វិភាជទៅតាមអង្គភាពថវិកា នាយកដ្ឋាន ឬអង្គភាពជំនាញដោយផ្ទាល់**។
- *កំណត់ចំណាយមិនប្រចាំ ហើយត្រូវមានគម្រោងច្បាស់លាស់បញ្ជាក់ពីតម្រូវការ និងប្រសិទ្ធភាពនៃការបើប្រាស់ចំណាយមិនប្រចាំនេះ ព្រមទាំងមូលដ្ឋានគណនាតម្រូវការចំណាយនេះ ឱ្យបានច្បាស់លាស់*។ ចំណាយមិនជាប្រចាំគឺជាចំណាយដែលមិនត្រូវការចំណាយ ជារៀងរាល់ឆ្នាំ រួមមានការចំណាយបំពាក់ឧបករណ៍សម្ភារការិយាល័យ ឧបករណ៍សម្ភារដឹកជញ្ជូន សម្ភារបរិក្ខារបច្ចេកទេស គ្រឿងសង្ហារឹម និងឧបករណ៍សម្ភារប្រើប្រាស់ផ្សេងៗ ដែលជាចំណាយមិនត្រូវទិញ

ប្រចាំឆ្នាំព្រមទាំងចំណាយសម្រាប់ការជួសជុល បោះពុម្ព កិច្ចប្រជុំ សិក្ខាសាលា និង បេសកកម្មមួយចំនួនដែលមិនមែនជាសកម្មភាពជាប្រចាំឆ្នាំ។ ប្រភេទចំណាយមិនជាប្រចាំនេះ គួរកំណត់ឱ្យបានច្បាស់លាស់មានគម្រោង និងកាលវិភាគច្បាស់លាស់សម្រាប់ចំណាយប្រភេទនេះ សម្រាប់រយៈពេលមធ្យម និងមានមូលដ្ឋានគណនាតម្រូវការចំណាយត្រឹមត្រូវទៅតាមតម្រូវការជាក់ស្តែងរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល។

២៤- ជាមួយគ្នានេះដែរ ដើម្បីបង្កើនប្រសិទ្ធភាពចំណាយនៅដំណាក់កាលរៀបចំ និងចរចាថវិកា **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឱ្យកាត់ចេញនូវថវិកាប្រភេទចំណាយមិនជាប្រចាំ ផ្ទៃក្នុង** ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ។ ទំហំឥណទានដែលនៅសល់ក្នុងក្របខណ្ឌពិដាននេះ អាចជាកម្មវត្ថុនៃការវិភាជសម្រាប់កែលម្អ ឬបង្កើនប្រសិទ្ធភាពនៃកម្មវិធីដែលមានស្រាប់ ឬសម្រាប់កម្មវិធីបម្រើឱ្យគោលនយោបាយថ្មី នៅក្នុង**ក្រសួង-ស្ថាប័នដដែល ឬ ទៅ ក្រសួង-ស្ថាប័នមួយទៀត ឬពីមន្ទីរជំនាញនៃក្រសួងមួយ ទៅមន្ទីរជំនាញនៃក្រសួងមួយទៀតបាន** ក្នុងក្របខណ្ឌនៃវិស័យចំណាយតែមួយ។

២៥-ទន្ទឹមនេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលអនុវត្តថវិកាកម្មវិធី ត្រូវតែផ្តល់របាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាកម្មវិធីឆ្នាំ២០១៦ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្ត ហើយក៏ជាកម្មវត្ថុសម្រាប់ការលើកទឹកចិត្ត ឬ ការកាត់បន្ថយគម្រោងចំណាយឆ្នាំ២០១៨ផងដែរ។ *នៅពេលពិភាក្សា និងចរចាថវិកា ក្រសួង-ស្ថាប័ននីមួយៗត្រូវរៀបចំជាបទបង្ហាញអំពីរបាយការណ៍សមិទ្ធកម្មឆ្នាំ២០១៦ របាយការណ៍សមិទ្ធកម្មពាក់កណ្តាលឆ្នាំ២០១៧ និងការគ្រោងលទ្ធផលរំពឹងទុកសម្រាប់ឆ្នាំ២០១៨។*

២៦- ទន្ទឹមនេះដែរ ត្រូវផ្អែកលើមូលដ្ឋាននៃថវិកាឆ្នាំ២០១៧ ដែលកំពុងអនុវត្តស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ក្នុងការរៀបចំថវិកាឆ្នាំ២០១៨ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល អាចពិនិត្យផងដែរទៅដល់បម្រែបម្រួលនៃថវិកាក្នុងអំឡុងពេលអនុវត្ត ដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម៖

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងអនុវត្ត ដូចជាការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬ ពីជំពូកមួយទៅជំពូកមួយទៀត ផ្ទៃក្នុងឬពីកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៅកម្មវិធីអនុកម្មវិធី ចង្កោមសកម្មភាពមួយទៀត ដែលធ្វើឱ្យការបែងចែកឥណទានដើមនៃក្រសួង-ស្ថាប័ន ព្រមទាំងមន្ទីរជំនាញរាជធានី ខេត្ត មានការប្រែប្រួល,
- ការផ្ទេរឥណទានថវិកាបន្ថែម សម្រាប់ផលប្រយោជន៍របស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត។

២៧- ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលស្ថិតក្រោមក្រសួងស្ថាប័ននីមួយៗ ត្រូវពង្រឹងតួនាទីក្រុមការងារថវិការបស់ខ្លួន និងត្រូវផ្តល់កិច្ចសហការគ្នាទៅវិញទៅមកជាប្រចាំឱ្យបានពេញលេញក្នុងកម្រិតបច្ចេកទេស ជាមួយក្រុមការងារថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) សំដៅបង្កើនប្រសិទ្ធភាព និងភាពទាន់-

ពេលវេលានៃការរៀបចំថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ននីមួយៗ។

### ៣.៣- កាលវិភាគនៃការរៀបចំគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០១៨

២៨- រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលានូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨។ នៅក្នុងកិច្ចដំណើរការនេះ ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមពិភាក្សានិងចរចាគម្រោងថវិកាជាមួយក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងធ្វើការបូកសរុបចំណូល-ចំណាយ រៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨។ **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ហើយផ្ញើជូនគណៈរដ្ឋមន្ត្រីឱ្យបាននៅក្នុងសប្តាហ៍ទី១ នៃខែតុលា ឆ្នាំ២០១៧ ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច ហើយផ្ញើជូនរដ្ឋសភាឱ្យបានក្នុងសប្តាហ៍ទី១ នៃខែវិច្ឆិកា ឆ្នាំ២០១៧ ដើម្បីស្ថាប័ននីតិប្បញ្ញត្តិមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់នេះ ឱ្យបានមុនថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧។**

២៩- **ឯកសារផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៨-២០២០ និងគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០១៨** ដែលក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល បានផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាមូលដ្ឋានចាំបាច់មិនអាចខ្វះបានសម្រាប់**ការចរចាថវិកាកម្រិតបច្ចេកទេស/ ជំនាញ និង ការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង** ដើម្បីធ្វើយុត្តិកម្មកញ្ចប់ថវិការបស់ខ្លួន។ **ការចរចាថវិកា កម្រិតបច្ចេកទេស និង កម្រិតថ្នាក់ដឹកនាំនេះ នឹងត្រូវពិភាក្សាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច (ជំពូក គណនី និង អនុគណនី) និង/ឬ តាមចំណាត់ថ្នាក់កម្មវិធី (កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព)** លើមូលដ្ឋាននៃ គោលការណ៍និងវិធានការនៃការគ្រោងថវិកាដូចបានលម្អិតខាងលើ ដើម្បីធានាប្រសិទ្ធភាពនៃការវិភាជថវិកា ក្នុងកម្រិតនៃពិដានកញ្ចប់ថវិកាឆ្នាំ២០១៨ ដែលបានកំណត់និងក្នុងកម្រិតលទ្ធភាពថវិកាជាតិទ្រទ្រង់បាន។ ដូច្នេះ ក្នុងករណីដែលក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលណាមួយ មិនបានបំពេញ និងផ្តល់ព័ត៌មានគ្រប់គ្រាន់ទៅតាមគោលការណ៍ និងតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្តនោះឱ្យបានទាន់ពេលវេលា ដើម្បីធ្វើការបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេ នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការយកមូលដ្ឋាននៃឥណទាន ថវិកាឆ្នាំ២០១៧ ដោយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូកខាងលើ សម្រាប់កំណត់គម្រោងថវិការបស់ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញ រាជធានី ខេត្តនោះ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ឱ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ។ តួលេខគម្រោងចំណូល-ចំណាយថវិកា ត្រូវសរសេរជាលេខអន្តរជាតិ (1, 2, 3...) ហើយឯកតាទាបបំផុតគិតត្រឹម 0,1 លានរៀល។

## ៤. សេចក្តីសន្និដ្ឋាន

៣០- ខ្លឹមសារនៃសារាចរណែនាំនេះ បានកំណត់ក្របខណ្ឌ និងវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេស ក្នុងការគ្រោងចំណូល និងចំណាយចាំបាច់ សម្រាប់ជាមូលដ្ឋានដល់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីរៀបចំផែនការសកម្មភាពការងារប្រចាំ

ឆ្នាំរបស់ខ្លួន សំដៅធ្វើយ៉ាងណាសម្រេចឱ្យបានជោគជ័យនូវគោលបំណងនៃគោលនយោបាយ និងកម្មវិធីដើម្បីរួមចំណែកសម្រេចឱ្យបានគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល គឺរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលវែង ប្រកបដោយចីរភាពក្នុងរង្វង់ ៧% និង កាត់បន្ថយភាពក្រីក្រឱ្យបានលើស ១% ក្នុងមួយឆ្នាំៗ ព្រមទាំងបន្ត រក្សាឱ្យបាននូវស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានគ្រឹះ និងចាំបាច់បំផុតក្នុងការឈានទៅសម្រេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាល គឺភាពសុខដុមរមនាសង្គម និងសុខុមាលភាពប្រជាជន។

៣១- ទោះជាយ៉ាងណាក៏ដោយ ដើម្បីឱ្យគោលដៅទាំងឡាយដែលបានដាក់ចេញក្នុងសារាចរនេះអាចអនុវត្តសម្រេចបានជោគជ័យ ថ្នាក់ដឹកនាំគ្រប់ក្រសួង-ស្ថាប័ន និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ចាំបាច់ត្រូវខិតខំថែមទៀតប្រកបដោយឆន្ទៈប្តូរប្តេជ្ញ ពិសេស ត្រូវតែផ្លាស់ប្តូរឥរិយាបទនិងផ្នត់គំនិតក្នុងការរៀបចំថវិកា ដោយខិតខំគោរពឱ្យបានខ្ជាប់ខ្ជួនតាមក្របខណ្ឌ និងបណ្តាវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេសទាំងឡាយ ទាំងផ្នែកចំណូល និងផ្នែកចំណាយ ដែលកំណត់ដោយសារាចរណែនាំនេះ។ ទន្ទឹមនេះ គ្រប់ក្រសួង-ស្ថាប័ន ត្រូវបន្តជំរុញការលើកកម្ពស់អភិបាលកិច្ចល្អនៅក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ ដើម្បីមិនត្រឹមតែអាចបង្កើនសក្តានុពលនៃតួនាទីរបស់ថវិកា ដែលជាឧបករណ៍សម្រាប់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេស **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣** ប៉ុណ្ណោះទេ ថែមទាំងអាចធ្វើជាជន្ទល់ដ៏រឹងមាំសម្រាប់ទ្រទ្រង់ដល់ការដ្ឋានកម្មវិធីកែទម្រង់ដទៃទៀត ដោយរួមទាំងដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋផងដែរ។

៣២- ពេលទទួលសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំជាបន្ទាន់នូវគម្រោងចំណូល-ចំណាយថវិការបស់ខ្លួន សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្ម នៃអគ្គនាយកដ្ឋានថវិកា) **ចំនួនពីរច្បាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៧** ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាថវិកាកម្រិតបច្ចេកទេស/ជំនាញ និងបូកសរុប ហើយអាចចាប់ផ្តើមដំណើរការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន ទាន់ពេលវេលាកំណត់។ ក្នុងការអនុវត្តសារាចរណែនាំនេះ ប្រសិនបើក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំង គ្រឹះស្ថានសាធារណៈរដ្ឋបាល មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា)។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
"ដើម្បីជូនជ្រាប"
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
-គ្រប់មន្ទីរជំនាញរាជធានី ខេត្ត
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ